# ប្រវត្តិសាស្ត្រកម្ពុជា

## កម្រងសំណួរ និងចម្លើយ



ឆ្នាំ ២០២១

រៀបរៀងដោយ អេងឡាយ

១.តើប្រទេសកម្ពុជាទទួលបានឯករាជ្យពេញលេញនៅឆ្នាំណា?

ប្រទេសកម្ពុជាទទួលបានឯករាជ្យពេញលេញនៅឆ្នាំ ១៩៥៣ ( ថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣ ) ។

២.តើការទទួលបានឯករាជ្យនេះ មានអត្ថន័យដូចម្តេចខ្លះចំពោះកម្ពុជា?

ឯករាជ្យឆ្នាំ ១៩៥៣ មានអត្ថន័យជាប្រវត្តិសាស្ត្រចំពោះកម្ពុជាដូចជា៖

- ជាថ្ងៃដែលប្រជាជនកម្ពុជារួចផុតពីការគាបសង្កត់ ការបង្ខំឲ្យបង់ពន្ធយ៉ាងធ្ងន់ធ្ងរសព្វសារពើពីសំណាក់បារាំង។
- ប្រជាជនមានសិទ្ធិសេរីភាព និងមានសិទ្ធិក្នុងការសម្រេចជោគវាសនាប្រទេសជាតិដោយខ្លួនឯង
- ប្រជាជនកម្ពុជារក្សាបាននូវប្រពៃណី ទំនៀមទម្លាប់ ជំនឿ សាសនា របស់ជាតិខ្លួន។
- ប្រទេសកម្ពុជារួចផុតពីអាណាព្យាបាលបារាំង។
- ប្រទេសកម្ពុជាទទួលបានឯករាជ្យ អធិបតេយ្យភាព និងបូរណភាពទឹកដី។
- កម្ពុជាបានដឹកនាំអភិវឌ្ឍជាតិខ្លួនស្របតាមឆន្ទៈ និងគោលបំណងរបស់ប្រជាជន។
- កម្ពុជាបានឈរស្មើមុខស្មើមាត់លើឆាកអន្តរជាតិ។

៣.ចូរពណ៌នាពីមូលហេតុដែលកម្ពុជាទទួលយកអាណានិគមនិយមបារាំង?

មូលហេតុដែលកម្ពុជាទទួលយកអាណានិគមនិយមបារាំង

- នយោបាយ
  - សៀម-យួន គាបសង្កត់ និងឈ្លានពានកម្ពុជា
  - ខ្មែរយកមហាអំណាចអឺរ៉ុបដើម្បីជាបង្អែកការពារប្រទេស
  - ធ្វើឲ្យមានឯកភាពអំណាចរាជបល្ល័ង្ក
- សេដ្ឋកិច្ច
  - សេដ្ឋកិច្ចខ្មែរធ្លាក់ចុះ ដោយសារការគាបសង្កត់ពីសំណាក់សៀម-យួន
  - បារាំងបើកប្រាក់បៀវត្សឲ្យមន្ត្រីរាជការ និងរាជវង្ស ព្រះមហាក្សត្រខ្ពស់
  - បារាំងជាអ្នកពាណិជ្ជកម្មក្នុង និងក្រៅប្រទេសព្រមទាំងជាអ្នកកាន់កាប់ពន្ធដារ
- សង្គម
  - រៀបចំប្រព័ន្ធតុលាការថ្នាក់ឃុំ ដល់ខេត្តក្រុង
  - រៀបចំប្រព័ន្ធរដ្ឋបាល ថ្នាក់មូលដ្ឋានខេត្ត ក្រុង
  - សង្គមខ្មែរមានអស្ថិរភាព

    (សិស្សអាចមាន មតិពាក់ព័ន្ធនិង៖ វប្បធម៌ អក្សរសាស្ត្រខ្មែរ ការអប់រំ...)

៤.ចូរអត្ថាធិប្បាយពីចំណុចវិជ្ជមាន និងអវិជ្ជមាននៃរបបអាណាព្យាបាលបារាំង?

ចំណុចវិជ្ជមាន និងអវិជ្ជមាននៃរបបអាណាព្យាបាលបារាំង៖

- **ចំណុចវិជ្ជមាន**
  - បារាំងបានជួយការពារទឹកដី ពូជសាសន៍ខ្មែរឲ្យបានគង់វង្ស
  - បារាំងបានជួយកែទម្រង់រដ្ឋបាល ប្រព័ន្ធសេដ្ឋកិច្ច អប់រំសិក្សាធិការ រៀបចំសង្គមខ្មែរឲ្យមានរបៀប រៀបរយ មានសណ្តាប់ធ្នាប់បានរីកចម្រើនល្អប្រសើរជាងមុន
  - បារាំងបានជួយសាងសង់ផ្លូវថ្នល់ ស្ពាន មន្ទីរពេទ្យ សារមន្ទីរជាតិ ហោជ្ញារចនាសម្ព័ន សាលារៀន បណ្តុះបណ្តាលធនធានមនុស្ស
  - តាមរយៈសាលាចុងបូព៌ា ប្រទេសបារាំងបានសិក្សាស្រាវជ្រាវ ចងក្រងជួសជុសប្រាង្គ ប្រាសាទ អភិរក្សវប្បធម៌ អរិយធម៌ខ្មែរ ព្រមទាំងបានផ្សព្វផ្សាយទៅលើឆាកអន្តរជាតិធ្វើឲ្យពិភពលោកស្គាល់ប្រទេសកម្ពុជា
  - ក្នុងនាមអាណាព្យាបាលខ្មែរបារាំងបានយកទឹកដីពីសៀមឈ្លានពានមកឲ្យខ្មែរវិញដូចជា៖
    - ថ្ងៃទី ១៣ ខែកុម្ភៈ ឆ្នាំ១៩០៤ យកខេត្តត្រាត កោះកុង ម្លូព្រៃ ទន្លេរពៅ និងស្ទឹងត្រែង
    - ថ្ងៃទី ២៣ ខែមីនា ឆ្នាំ១៩០៧ យកខេត្តសៀមរាប បាត់ដំបង សិរីសោភណ្ឌ
  - ឆ្នាំ ១៩០៨ បារាំងបានគូសផែនទីឈ្មោះ " ដងរ៉ែក " ទុកជាប្រយោជន៍ដល់កម្ពុជា។ ផែនទីនេះនាំឲ្យខ្មែរឈ្នះក្តីក្នុងរឿងក្តីក្តាំប្រាសាទព្រះវិហារ។
- **ចំណុចអវិជ្ជមាន**
  - បារាំងបានធ្វើឲ្យប្រជាជនកម្ពុជាកាន់តែក្រីក្រដោយសារតែការជិះជាន់កេងប្រវ័ញ្ច ប្រមូលពន្ធដារយ៉ាងធ្ងន់ធ្ងរសព្វសារពើរ
  - បារាំងបានធ្វើឲ្យមានគម្លាតគ្នារវាងអ្នកទីក្រុង និងអ្នកជនបទ អ្នកមាន និងអ្នកក្រ បង្កើតទំនាស់វណ្ណៈក្នុងសង្គមខ្មែរយ៉ាងធ្ងន់ធ្ងរ
  - បារាំងបានកេណ្ឌប្រជាពលរដ្ឋខ្មែរឲ្យទៅច្បាំងស្លាប់ ក្នុងសមរភូមិសង្គ្រាមលោកលើកទី១ និងសង្គ្រាមលោកលើកទី២
  - បារាំងបានប្រមូលយកវត្ថុកេតណភណ្ឌខ្មែរទៅប្រទេសបារាំង
  - បារាំងបានកាត់ដីខ្មែរឲ្យប្រទេសជិតខាងស្រេចតែចិត្តដោយពុំសួរយោបល់ខ្មែរដូចជា៖
    - ថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩០៧ កាត់ខេត្តត្រាតឲ្យទៅសៀម
    - ថ្ងៃទី៣១ ខែមករា ឆ្នាំ១៩៣៩ កាត់បញ្ចូល កោះត្រល់ ដាក់ចូលក្នុងដែនរដ្ឋបាលកូសាំងស៊ីន

- ថ្ងៃទី០៤ ខែមិថុនា ឆ្នាំ១៩៤៩ កាត់កម្ពុជាក្រោម ( កូសាំងស៊ីន) ឲ្យទៅអំណាចស្តេចបាវដាយវៀតណាម។

**៥**.ហេតុអ្វីបានជាកម្ពុជាចាំបាច់ស្វែងរកកិច្ចការពារ ពីបារាំងដោយចុះសន្ធិសញ្ញាអាណាព្យាបាជាមួយបារាំង?

បានជាកម្ពុជាចាំបាច់ស្វែងរកកិច្ចការពារពីបារាំងដោយចុះសន្ធិសញ្ញាអាណាព្យាបាលព្រោះ ៖

- ប្រទេសកម្ពុជាកាន់តែទន់ខ្សោយ ហើយទឹកដីខ្មែរកាន់តែរួមតូចទៅៗនិងមានវិបត្តិផ្ទៃក្នុង
- ប្រទេសសៀមនិងយួន ( **អាណ្ណាម** ) នៅតែប៉ុនប៉ងរំលាយជាតិសាសន៍ខ្មែរឈ្លានពានទឹកដីខ្មែរ ដោយយកទន្លេមេគង្គធ្វើជាព្រំប្រទល់នៃប្រទេសទាំងពីរ
- ចង់បានមហាអំណាចអឺរ៉ុបណាមួយ(បារាំង)មកជួយការពារទឹកដី ពូជសាសន៍ខ្មែរ
- ដោយមានការណែនាំពីបុព្វជិតសាសនាកាតូលិកនាម មីស ( MICHE) ធ្វើឲ្យព្រះអង្គ**ដួង** ( **Ang Duong** ) ពឹងបារាំង ។

( មានចម្លើយត្រឹមត្រូវផ្សេងៗទៀត)

**៦**.ចូរពណ៌នាពីចលនាតស៊ូទាមទារឯករាជ្យពីបារាំងនៅកម្ពុជា។

ពណ៌នាពីចលនាតស៊ូទាមទារឯករាជ្យពីបារាំងនៅកម្ពុជាមានៈ

- ការតស៊ូដោយហិង្សា

  គឺជាចលនាតស៊ូដោយប្រើអាវុធ ប្រយុទ្ធបង្ហូរឈាមដើម្បីទាមទារឯករាជ្យ ដោយចលនាតស៊ូរបស់ខ្មែរឥស្សរៈ ដែលក្រុមនេះបានពង្រីកក្រុមខ្លួនទូទាំងប្រទេស។

- ការតស៊ូដោយអហិង្សា
  - គឺជាចលនាតស៊ូដោយសន្តិវិធី តាមរយៈមធ្យោបាយការទូត ពោលគឺតាមរយៈនយោបាយក្រៅប្រទេសជាមួយបារាំង កាណាដា សហរដ្ឋអាមេរិក ថៃ តាមរយៈនយោបាយការទូត និងកាសែត
  - ព្រះបាទនរោត្តមសីហនុ បានមានបន្ទូលថា " បើបារាំងមិនប្រគល់ឯករាជ្យឲ្យកម្ពុជាទេ...នោះប្រទេសកម្ពុជាក្លាយជាប្រទេសកុម្មុយនីស្ត "
  - សកម្មភាពក្នុងប្រទេសព្រះអង្គបានគង់នៅតំបន់ស្វយ័តក្នុងខេត្តសៀមរាប បាត់ដំបង កំពង់ធំដោយមិនយាងមកភ្នំពេញ ហើយទ្រង់បានបង្កើត កងជីវពល នារីក្លាហាន ដើម្បីឲ្យប្រជារាស្ត្រក្រោកឡើងទាមទារឯករាជ្យបរិបូរណ៍។

(មានចម្លើយត្រឹមត្រូវផ្សេងៗទៀត)

**៧.ចូរពណ៌នាពីសមិទ្ធផលសង្គមរាស្ត្រនិយមពីឆ្នាំ១៩៥៣ ដល់ ១៩៧០។**

ពណ៌នាពីសមិទ្ធផល នៃរបបសង្គមរាស្ត្រនិយម៖

❖ វិស័យនយោបាយ

- ប្រារព្ធសមាជជាតិ ធ្វើឲ្យមានការអភិវឌ្ឍជាតិលើគ្រប់វិស័យស្របតាមឆន្ទៈប្រជាជន
- ការអនុវត្តនយោបាយអព្យាក្រឹត បានធ្វើឲ្យប្រទេសជាតិមានសុខសន្តិភាពរយៈពេល១៥ឆ្នាំ (១៩៥៥-១៩៧០) ស្របពេលដែលប្រទេសជិតខាងជួបនិងសង្គ្រាម
- កម្ពុជាបានចូលជាសមាជិកអង្គការសហប្រជាជាតិ (១៤ ធ្នូ ១៩៥៥)
- កម្ពុជាឈ្នះក្តី ក្នុងរឿងក្តីក្តាំងប្រាសាទព្រះវិហារ (១៥ មិថុនា ១៩៦២)

❖ វិស័យសេដ្ឋកិច្ច

- កសិកម្ម ៖ ការអនុវត្តនយោបាយទឹក បានបង្កើតប្រព័ន្ធធារាសាស្ត្រខ្វាត់ខ្វែង ការពង្រីកដីដាំដុះធ្វើឲ្យមានកំណើនទិន្នផល
- ឧស្សាហកម្ម ៖ កំណើនរោងចក្រឧស្សាហកម្មជាច្រើនដូចជា រោងចក្រក្រដាស វាយនភណ្ឌ ក្តារបន្ទះ ស៊ីម៉ងត៍ ស្រាបៀរ តម្លើងត្រាក់ទ័រ បារីក្រចៅ...
- ពាណិជ្ជកម្ម ៖ នាំចេញនូវផលិតផលកសិកម្ម ដូចជា ស្រូវ អង្ករ ម្រេច កប្បាស បារីក្រចៅ
- ធនាគារ-ហិរញ្ញវត្ថុ ៖ លេចឡើងនៅធនាគារឯកជនជាច្រើន និងប្រាក់រៀលក្លាយជារូបិយវត្ថុជាតិប្រើប្រាស់ជាផ្លូវការ
- វិស័យសមាគម៍ ៖ សាងសង់ផ្លូវជាតិ ផ្លូវដែក ស្ពាន កំពង់ផែ អាកាសយានដ្ឋាន...

❖ វិស័យអប់រំ វប្បធម៌

- អប់រំសិក្សាធិការ ៖ បង្កើតសាលារៀនពីទីក្រុងរហូតដល់ជនបទ ពីមតេយ្យដល់ឧត្តមសិក្សា មានកំណើនធនធានមនុស្ស
- ផ្នែកកីឡា ៖ បង្កើតពហុកីឡដ្ឋានជាតិ ពហុកីឡដ្ឋានតាមខេត្ត ស្រុក សាលារៀន និងកន្លែងសម្រាប់កីឡាករហ្វឹកហាត់ស្នាក់នៅ
- សាសនា ៖ បង្កើតវត្តអារាមជាច្រើន និងពុទ្ធិកបឋមសិក្សា ដល់មធ្យមសិក្សា
- សិល្បៈ ៖ បង្កើតសាលាសិល្បៈ រោងមហាស្រព នៅតាមទីរួមខេត្ត និងធ្វើការជួសជុលប្រាង្គប្រាសាទបុរាណ អភិរក្សសម្បត្តិវប្បធម៌

❖ វិស័យសង្គម

- សុខភាពជាបញ្ហាចម្បង ដូចនេះរាជរដ្ឋាភិបាលបានបង្កើតមន្ទីរពេទ្យជាច្រើន ព្រមទាំងចាត់វិធានការចាក់ថ្នាំការពារ និងអនាម័យលំនៅដ្ឋាន

- បង្កើតច្បាប់រក្សាសន្តិសុខ សណ្តាប់ធ្នាប់សង្គម
- បង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ និងមជ្ឈមណ្ឌលអប់រំស្ត្រីពេស្យា
- ផ្តល់សិទ្ធិឲ្យស្ត្រីក្នុងការបោះឆ្នោត និងឈរឈ្មោះបោះឆ្នោត ( ៦ មករា ១៩៥៨ )

៨.អ្វីទៅជាគោលនយោបាយអព្យាក្រឹត? ចូរអ្នកពណ៌នា។

នយោបាយអព្យាក្រឹត នៅក្នុងរបបសង្គមរាស្ត្រនិយម៖

- នយោបាយអព្យាក្រឹត
  - នយោបាយអព្យាក្រឹត គឺជាការរួមរស់ដោយសន្តិសហវិជ្ជាមានជាមួយបណ្តាលប្រទេសនានាលើពិភពលោក ដោយនៅកណ្តាលមិនប្រកាន់មនោគមវិជ្ជាសេរី មនោគមវិជ្ជាកុម្មុយនីស្ត។
  - មូលហេតុនៃការអនុវត្តនយោបាយអព្យាក្រឹត
    - អនុវត្តទៅតាមសេចក្តីសម្រេចនៃសន្និសីទក្រុងហ្សឺណែវឆ្នាំ ១៩៥៤ ដែលស្នើដោយ ចិន និងសូវៀត
    - កម្ពុជាចង់រួមរស់ដោយសន្តិសហវិជ្ជមាន ជាមួយបណ្តាប្រទេសនានាលើពិភពលោក ពិសេសជាមួយប្រទេសជិតខាង។
  - ការពង្រឹងនយោបាយអព្យាក្រឹត
    - ថ្ងៃទី ១៨ ខែមីនា ឆ្នាំ១៩៥៥ ក្នុងដំណើរទស្សនកិច្ចនៅឥណ្ឌា សម្តេច នរោត្តម សីហនុ បានចុះហត្ថលេខាជាមួយលោក **នេរូ** លើសេចក្តីប្រកាសរួមគឺជាការរួមរស់ជាមួយគ្នាដោយសន្តិភាព
    - ថ្ងៃទី ១៨-២៤ ខែមេសា ឆ្នាំ១៩៥៥ ក្នុងសន្និសីទកំពូលនៃទ្វីបអាស៊ី-អាហ្វ្រិកនៅក្រុងបានឌុង សម្តេច នរោត្តម សីហនុ បានធ្វើសេចក្តីអះអាងពីកម្មវិធីនយោបាយអព្យាក្រឹតរបស់កម្ពុជា និងការរួមរស់ជាមួយគ្នាដោយសន្តិភាព
    - ថ្ងៃទី ១៤ ខែធ្នូ ឆ្នាំ១៩៥៥ ក្នុងពេលកម្ពុជាចូលជាសមាជិកអង្គការសហប្រជាតិ តំណាងរាជរដ្ឋាភិបាលកម្ពុជាបានប្រកាសពីមាគ៌ាអព្យាក្រឹតភាពនៃកម្ពុជា
    - ថ្ងៃទី ១-៦ ខែកញ្ញា ឆ្នាំ១៩៦១ សម្តេចនរោត្តម សីហនុ បានចុះហត្ថលេខាលើ ធម្មនុញ្ញនៃចលនាមិនចូលបក្សសម្ព័ន្ធ នៅប្រទេស **យូហ្គោស្លាវី**
  - លទ្ធផលនៃការប្រកាន់នយោបាយអព្យាក្រឹត
    - ជំហានដំបូង
      - មានការអភិវឌ្ឍប្រទេសលើគ្រប់វិស័យ
      - ប្រទេសកម្ពុជាមានសុខសន្តិភាពរយៈពេល១៥ឆ្នាំ

- កម្ពុជាមានឈ្មោះល្បីសុះសាយក្នុងតំបន់
- ក្រុមអ្នកប្រឆាំងពុំហ៊ានប៉ះពាល់ និងទទួលស្គាល់គុណសម្បត្តិនយោបាយអព្យាក្រឹត

• ដំណាក់កាលសង្រ្គាមត្រជាក់

- ឥទ្ធិពលនៃសង្រ្គាមត្រជាក់ មហាអំណាចមនោគមវិជ្ជាទាំងពីរ ពុំទុកកម្ពុជាក្នុងមាគ៌ាសន្តិភាព មាគ៌ាអព្យាក្រឹត
- សហរដ្ឋអាមេរិក ថៃ វៀតណាមខាងត្បូង វៀតណាមខាងជើង ធ្វើសកម្មភាពប្រឆាំង និងនយោបាយអព្យាក្រឹត ដែលធ្វើឲ្យកម្ពុជាអនុវត្តនយោបាយអព្យាក្រឹតមិនចំទិសដៅ និងនាំកម្ពុជាទៅធ្លាក់ក្នុងភ្លក់ភ្លើងនៃសង្រ្គាម។

(មានចម្លើយត្រឹមត្រូវផ្សេងៗទៀត)

៩.ចូរពណ៌នាពីសម័យសង្គមរាស្ត្រនិយម (១៩៥៥-១៩៧០)។

ពណ៌នាពីសម័យសង្គមរាស្ត្រនិយម (១៩៥៥-១៩៧០)

**❖ ការបង្កើតរបបសង្គមរាស្ត្រនិយម**

- រដ្ឋធម្មនុញ្ញឆ្នាំ ១៩៤៧ បានបញ្ញត្តពីអំណាចព្រះមហាក្សត្រដោយ រាល់ទស្សនៈនយោបាយរបស់ព្រះមហាក្សត្រត្រូវដាក់ឲ្យអនុម័ត ទើបយកទៅអនុវត្ត
- សភាតែងតែជំទាស់រាល់គំនិតទស្សនៈនយោបាយរបស់ព្រះមហាក្សត្រ
- ព្រះរាជា ពុំចង់ឃើញការខ្វែងគំនិតគ្នា និងការបែកបាក់គ្នា ក្នុងរង្វង់អ្នកដឹកនាំ
- ព្រះរាជាចង់ឲ្យប្រជាជន អ្នកនយោបាយគ្រប់និន្នាការ រួបរួមគ្នាស្ថិតក្រោមម្លប់រាជបល្ល័ង្កតែមួយ
- ដូច្នេះហើយ បានជាព្រះអង្គដាក់រាជ្យ នៅថ្ងៃទី ៣ ខែមីនា ឆ្នាំ១៩៥៥ ហើយបង្កើតអង្គការសង្គមរាស្ត្រនិយម ថ្ងៃទី ២៣ ខែមីនា ឆ្នាំ១៩៥៥ ដោយចូលរួមបោះឆ្នោតនៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ១៩៥៥ ទទួលបានជោគជ័យ ៨៣.៨៧ ភាគរយ។ សង្គមរាស្ត្រនិយមក៏បានកើតឡើង។

**❖ សមាជជាតិ**

- ជាវេទិកាលទ្ធិប្រជាធិបតេយ្យដែលតម្រូវឲ្យប្រជាជនគ្រប់ស្រទាប់វណ្ណៈគ្រប់និន្នការនយោបាយចូលរួមបញ្ចេញមតិយោបល់ជាមួយថ្នាក់ដឹកនាំជាតិ ដើម្បីប្រយោជន៍រួមរបស់ជាតិ
- សមាជជាតិត្រូវបានប្រារព្ធឡើងមួយឆ្នាំពីរដង ដោយទទួលបានផ្លែផ្កាជាវិជ្ជមាន

**❖ នយោបាយអព្យាក្រឹត នៅកម្ពុជា៖**

- គោរពតាមស្មារតីសន្និសីទក្រុងហ្សឺណែវ ឆ្នាំ១៩៥៤
- ដើម្បីរក្សាសន្តិភាពនៅកម្ពុជា
- ដើម្បីរួមរស់ដោយសន្តិសហវិជ្ជមាន

- មានសន្តិភាព រយៈពេល១៥ឆ្នាំ
- ទប់ទល់និងឥទ្ធិពលសង្គ្រាមត្រជាក់
- ឥទ្ធិពលនៃសង្គ្រាមត្រជាក់ ធ្វើឲ្យនយោបាយអព្យាក្រឹតដួលរលំ

❖ **សមិទ្ធផល** ៖ មានការរីកចម្រើនលើគ្រប់វិស័យដូចជា

- វិស័យនយោបាយ
  - ការប្រារព្ធសមាជជាតិ ធ្វើឲ្យមានការអភិវឌ្ឍជាតិលើគ្រប់វិស័យស្របតាមឆន្ទៈប្រជាជន
  - ការអនុវត្តនយោបាយអព្យាក្រឹត ធ្វើឲ្យប្រទេសជាតិបានសុខសន្តិភាពរយៈពេល១៥ឆ្នាំ (១៩៥៥-១៩៧០)
  - កម្ពុជាបានចូលជាសមាជិកអង្គការសហប្រជាជាតិ (១៤ ធ្នូ ១៩៥៥)
  - កម្ពុជាឈ្នះក្តី ក្នុងរឿងក្តីក្តាំប្រាសាទព្រះវិហារ (១៥ មិថុនា ១៩៦២)
- វិស័យសេដ្ឋកិច្ច ៖ រីកចម្រើនផ្នែក កសិកម្ម ពាណិជ្ជកម្ម ឧស្សាហកម្ម និងភាពរីកចម្រើនផ្នែកអហរ័ណ នីហរ័ណជាតិ
- គមនាគមន៍ ៖ ផ្លូវទឹក គោក អាកាស
- វិស័យធនាគារ ៖ប្រាក់រៀលត្រូវបានចរាចរណ៍នៅទូទាំងប្រទេស
- វស័យវប្បធម៌ ៖ រីកចម្រើនផ្នែក សិក្សាធិការ កីឡា សិល្បៈ
- សង្គមកិច្ច ៖ ផ្តោតលើបញ្ហាពីរ គឺសុខាភិបាល និងការអនុវត្តច្បាប់។

**១០**.តើរដ្ឋប្រហានៅឆ្នាំ ១៩៧០-១៩៧៥ បាននាំមកអ្វីខ្លះសម្រាប់ប្រទេសកម្ពុជា?

រដ្ឋប្រហារពុំបាននាំប្រទេសកម្ពុជាទៅរកដំណោះស្រាយ និងភាពចម្រុងចម្រើននោះទេ មានតែនាំមកនូវសង្គ្រាមស៊ីវិល ការបាត់បង់ខូចខាត និងវិនាសកម្មដូចជា៖

➢ **ខាងសង្គម**

- ការបែកបាក់សាមគ្គីជាតិ
- បាតុកម្ម កូដកម្ម កុប្បកម្ម ដែលបង្កនូវការច្របូកច្របល់ភាពអនាធិបតេយ្យទូទាំងប្រទេស
- ប្រជាជនរងទុក្ខវេទនា ព្រាត់ប្រាស់គ្រួសារ ផ្ទះសម្បែង រងគ្រោះទុរ្ភិក្ស
- ប្រជាជនរស់ដោយប្រឈមមុខ និងមនោគមវិជ្ជានៃសង្គ្រាមត្រជាក់ សឹកសង្គ្រាម ការទម្លាក់គ្រាប់បែកពីសហរដ្ឋអាមេរិក
- ប្រជាជនមួយចំនួនរត់ចូលក្នុងព្រៃតាមការអំពាវនាវរបស់សម្តេច នរោត្តម សីហនុ ឯខ្លះទៀតភៀសខ្លួនមកកាន់ទីក្រុងភ្នំពេញ រស់នៅដោយកង្វះអាហារ បាត់បង់ការងារ..

- **ខាងសេដ្ឋកិច្ច**

  រដ្ឋប្រហារធ្វើឲ្យសេដ្ឋកិច្ចកម្ពុជាជាប់គាំងដោយៈ
  - ដីស្រែចម្ការទំនេរទុកទំនេរចោល ទិន្នផលធ្លាក់ចុះ
  - រោងចក្រសហគ្រាសត្រូវបិទទ្វា
  - ទំនិញឡើងថ្លៃ អតិផរណា
- **ខាងនយោបាយ**
  - កម្ពុជាបាត់បង់កេរ្តិ៍ឈ្មោះ កិត្តិយសលើឆាកអន្តរជាតិ
  - អស្ថិរភាពខាងនយោបាយធ្វើឲ្យប្រជាជនបាត់បង់ជំនឿលើអ្នកដឹកនាំ
  - កម្ពុជាបាត់បង់ឯករាជ្យ អធិបតេយ្យ បូរណភាពទឹកដី
  - មានការផ្លាស់ប្តូររបបនយោបាយ
  - ជាការបើកផ្លូវឲ្យខ្មែរក្រហមឡើងកាន់អំណាច ដែលនាំឲ្យកម្ពុជាទៅរកការសម្លាប់រង្គាលក្នុងរបបប្រល័យពូជសាសន៍។

( មានចម្លើយត្រឹមត្រូវផ្សេងៗទៀត )

**១១**.ចូរពណ៌នាពីមូលហេតុដែលធ្វើឲ្យសង្គ្រាមស៊ីវិលផ្ទុះឡើងពីឆ្នាំ ១៩៧០-១៩៧៥។

មូលហេតុដែលធ្វើឲ្យសង្គ្រាមស៊ីវិលផ្ទុះឡើងពីឆ្នាំ ១៩៧០-១៩៧៥ៈ

- ដោយសារឥទ្ធិពលសង្គ្រាមត្រជាក់
- ការអនុវត្តនយោបាយអព្យាក្រឹតរបស់ សម្តេចនរោត្តម សីហនុ មិនចំទិសដៅ ឬលម្អៀង
- រដ្ឋប្រហារទម្លាក់ សម្តេច នរោត្តម សីហនុ (១៨ មីនា ១៩៧០ )
- អំពើពុករលួយ បក្សពួកនិយម បាតុកម្ម កុប្បកម្មពេញផ្ទៃប្រទេស
- មន្ត្រីរបស់ សម្តេច នរោត្តម សីហនុ ក្បត់និងព្រះអង្គ
- ការជ្រៀកជ្រែករបស់វៀតណាម ចិន សហរដ្ឋអាមេរិក ក្នុងនយោបាយខ្មែរ
- ការបង្កើត រណសិរ្សរួបរួមជាតិកម្ពុជា របស់សម្តេចនរោត្តម សីហនុ។

( ចំណុចផ្សេងៗទៀត )

**១២**.តើសង្គ្រាមស៊ីវិលពីឆ្នាំ ១៩៧០-១៩៧៥ មានផលវិបាកអ្វីខ្លះសម្រាប់កម្ពុជា?

សង្គ្រាមស៊ីវិលពីឆ្នាំ ១៩៧០-១៩៧៥ បាននាំមកនូវការខូតខាតនិងវិនាសកម្មយ៉ាងធ្ងន់ធ្ងរ ដល់កម្ពុជាដូចជាៈ

- **វិនាសកម្មខាងសង្គម**
  - សម្លាប់ជីវិតមនុស្សអស់រាប់លាននាក់ និងធ្វើឲ្យមានរបួស ពិការជាច្រើន

- បន្សល់នៅស្ត្រីមេម៉ាយ ក្មេងកំព្រា ចាស់ជរាគ្មានទីពឹង
- ប្រជាជនរងទុក្ខវេទនា ព្រាត់ប្រាស់គ្រួសារ ផ្ទះសម្បែង ជួបគ្រោះទុរ្ភិក្ស
- បំផ្លាញផ្ទះសម្បែង វត្តអារាម សាលារៀន គ្រឹះស្ថានសាធារណៈ មន្ទីរពេទ្យ
- បំបាត់សិទ្ធិសេរីភាព
- ជួបនៅអនាធិបតេយ្យ ចោរកម្ម ពុករលួយ អយុត្តិធម៌
- បំផ្លាញធនធានមនុស្ស...

❖ **ការខូចខាតខាងសេដ្ឋកិច្ច**

- ដីស្រែចម្ការទុកទំនេរចោល និងក្លាយជាចម្ការមីន រណ្ដៅគ្រាប់បែក
- សំណង់ធារាសាស្ត្រ សំណង់បរិក្ខា ស្ពាន ផ្លូវថ្នល់ កំពង់ផែ ត្រូវខ្ទេចខ្ទាំ
- កសិដ្ឋាន រោងសិប្បកម្ម រោងចក្រសហគ្រាស ត្រូវបំផ្លាញ
- ចម្ការកៅស៊ូ ត្រូវខូចខាត វិស័យពាណិជ្ជកម្មត្រូវរាំងស្ទះ
- បាត់បង់ធនធាន និងអ្នកវិនិយោគមិនបានចូលមកដាក់ទុន
- ទំនិញឡើងថ្លៃ អតិផរណា...

❖ **ខាងនយោបាយ ៖** អស្ថិរភាពខាងនយោបាយ  បាននាំមកនូវ៖

- ការបាត់បង់កត្តិយស កេរ្តិ៍ឈ្មោះជាតិកម្ពុជាលើឆាកអន្តរជាតិ
- កម្ពុជាបាត់បង់ឯករាជ្យ អធិបតេយ្យភាព បូរណភាពទឹកដី
- ប្រជាជនអស់ទំនុកចិត្តលើអ្នកដឹកនាំ អស់សង្ឃឹមលើវាសនាជាតិខ្លួន
- នាំកម្ពុជាទៅរកការបែកបាក់ជាតិ ការសម្លាប់រង្គាលលើជាតិសាសន៍ឯង
  ( របបកម្ពុជាជាតិប្រជាធិបតេយ្យ )
- កម្ពុជា ជាប្រទេសរស់នៅដោយឯកោ...

**១៣**.ចូរពណ៌នាពីកត្តាសំខាន់ៗដែលធ្វើឲ្យរបបសាធារណរដ្ឋខ្មែរ(១៩៧០-១៩៧៥) ដួលរលំ។

កត្តាសំខាន់ៗបណ្ដាលឲ្យរបបសាធារណរដ្ឋខ្មែរដួលរលំ៖

- ប្រជាជននៅទីក្រុងភ្នំពេញ និងនៅតំបន់រំដោះនឿយណាយនិងរបបសាធារណរដ្ឋខ្មែរ ដែលពោរពេញដោយភាពអាប់អួរ
- ប្រជាជនៅក្រុងភ្នំពេញ រស់លើដីដ៏តូចចង្អៀត ដោយរងនូវ៖
  - កង្វះអាហារ កង្វះជម្រក បាត់បង់ការងារ
  - ទំនិញឡើងថ្លៃ អតិផរណា
  - អនាធិបតេយ្យភាព ចោរកម្ម អយុត្តិធម៌ ពុករលួយ បនល្បែងពាលា

- ភាពច្របូកច្របល់ បាតុកម្ម កូដកម្ម កុប្បកម្ម ពេញទីក្រុង
- រដ្ឋាភិបាល **លន់ នល់** គ្រប់គ្រងបានតែទីក្រុង និងទីប្រជុំជន ឯជនបទស្រែចម្ការគ្រប់គ្រងដោយបក្សកុម្មុនីស្តកម្ពុជា ( **ខ្មែរក្រហម** )
- សេដ្ឋកិច្ចរបបសាធារណរដ្ឋខ្មែរ មិនដំណើការ របបនេះរស់ដោយសារជំនួយពីសហរដ្ឋអាមេរិក
- ការដឹកជញ្ជូនស្បៀង សព្វាវុធ របស់សហរដ្ឋអាមេរិកដើម្បីជួយរដ្ឋាភិបាលលោក លន់ នល់ ត្រូវខ្មែរក្រហមកាត់ផ្តាច់ទាំងផ្លូវគោក និងផ្លូវទឹក
- ខ្មែរក្រហមធ្វើការហ៊ុមព័ទ្ធទីក្រុងភ្នំពេញ និងរឹតបន្តឹងការនាំស្បៀងចូល
- ការចចាររវាងតំណាងសាធារណរដ្ឋខ្មែរ និងតំណាងសម្តេចនរោត្តម សីហនុ ត្រូវបរាជ័យ
- ថ្ងៃទី១ ខែមេសា ឆ្នាំ១៩៧៥ លោក **លន់ នល់** បានភៀសខ្លួនទៅសហរដ្ឋអាមេរិក
- ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ កងទ័ពខ្មែរក្រហមចូលកាន់កាប់ទីក្រុងភ្នំពេញ។

( មានចម្លើយត្រឹមត្រូវផ្សេងៗទៀត )

**១៤**.ហេតុអ្វីបានជាកើតមានរដ្ឋប្រហារឆ្នាំ១៩៧០? តើរដ្ឋប្រហានេះផ្តល់ផលវិបាកដូចម្តេចខ្លះ?

មូលហេតុ និងផលវិបាកនៃរដ្ឋប្រហារឆ្នាំ ១៩៧០ ៖

- **ហេតុដែលនាំឲ្យមានរដ្ឋប្រហារឆ្នាំ ១៩៧០៖**

  មុនរដ្ឋប្រហារប្រទេសកម្ពុជា បានជួបវិបត្តិសង្គម សេដ្ឋកិច្ច នយោបាយ យ៉ាងធ្ងន់ធ្ងរដែលមិនអាចដោះស្រាយបាន ដូចជា៖

  - វិបត្តិសង្គម
    - ការបែកបាក់សាមគ្គីជាតិ ទៅតាមមនោគមវិជ្ជា ដែលសាបព្រួសដោយអ្នកនយោបាយ ( ខ្មែរក្រហម ខ្មែរខៀវ ខ្មែរស )
    - សង្គមជួបនូវអំពើពុករលួយ បក្ខពួកនិយម អនាធិបតេយ្យ អយុត្តិធម៌ ចោរកម្ម
    - ប្រជាជនរស់នៅតាមព្រំដែនកម្ពុជា-វៀតណាម រងនូវការទម្លាក់គ្រាប់បែក
    - ភាពចលាចល បាតុកម្ម កុប្បកម្ម ប្រឆាំងនិងវត្តមានប្រជាជន និងកងទ័ពវៀតណាមកាន់តែច្រើនឡើងលើទឹកដីកម្ពុជា
  - វិបត្តិសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

    សេដ្ឋកិច្ចជាតិធ្លាក់ចុះយ៉ាងខ្លាំងរើបលែងរួច ដោយសារ៖

    - ការធ្វើតូបនីយកម្មបានធ្វើឲ្យធនគារឯកជន ក្រុមហ៊ុនឯកជនត្រូវបានបិទទ្វារ ប្រជាជនឥតការងារធ្វើ

- រដ្ឋបាត់បង់ប្រាក់ចំណូល ដោយសារតែទំនិញគេចពន្ធ អំពើពុករលួយ ការបដិសេធជំនួយពីសហរដ្ឋអាមេរិក
- ការចំណាយ និងចំណូលខ្វះតុល្យភាព
- ទំនិញឡើងថ្លៃ អតិផរណាក្រដាសប្រាក់
- ការដឹកជញ្ជូនត្រូវរាំងស្ទះ

- វិបត្តិនយោបាយ

ឥទ្ធិពលនៃសង្គ្រាមត្រជាក់បានបណ្ដាលឲ្យ៖

- កម្ពុជាអនុវត្តន៍នយោបាយអព្យាក្រឹតមិនចំទិសដៅនិងលូកដៃចូលក្នុងសង្រ្គាមវៀតណាម
- អ្នកនយោបាយខ្មែរបែកបាក់សាមគ្គីជាតិ
- អ្នកនយោបាយខ្លះទៀតរៀបចំផែនការក្បត់សម្ដេច នរោត្ដម សីហនុ
- មានការផ្លាស់ប្ដូររាជរដ្ឋាភិបាលញឹកញាប់
- ខ្មែរក្រហម ពង្រឹងកម្លាំងនៅ ភូមិភាគឦសាន ឧត្ដរ ពាយ័ព្យ ហើយវាយប្រហារលើសង្គមរាស្ត្រនិយម ព្រមទាំងគ្រប់គ្រងទឹកដីបានមួយចំនួន
- រដ្ឋាភិបាលមិនអាចទប់ស្កាត់ការបោះបោររបស់ប្រជាជនប្រឆាំង និងវត្តមាន ប្រជាជន និងកងទ័ពវៀតណាម កាន់តែច្រើនឡើងនៅលើដីកម្ពុជា

➢ មូលហេតុខាងលើនេះបណ្ដាលឲ្យមានរដ្ឋប្រហារទម្លាក់សម្ដេច នរោត្ដម សីហនុ ពីប្រមុខរដ្ឋនាថ្ងៃទី ១៨ ខែមីនា ឆ្នាំ១៩៧០។

( មានចម្លើយត្រូវផ្សេងៗទៀត )

❖ **ផលវិបាកនៃរដ្ឋប្រហារឆ្នាំ១៩៧០ ៖**

រដ្ឋប្រហារពុំបាននាំប្រទេសកម្ពុជាទៅរកដំណោះស្រាយ និងភាពចម្រុងចម្រើននោះទេ មានតែនាំមកនូវសង្គ្រាមស៊ីវិលការបាត់បង់ខូចខាតនិងវិនាសកម្មដូចជា៖

- ខាងសង្គម
  - ការបែកបាក់សាមគ្គីជាតិ
  - បាតុកម្ម កូដកម្មកុប្បកម្មដែលបង្កនូវការច្របូកច្របល់ភាពអនាធិបតេយ្យទូទាំងប្រទេស
  - ប្រជាជនរងទុក្ខវេទនា ព្រាត់ប្រាស់គ្រួសារ ផ្ទះសម្បែង រងគ្រោះទុរ្ភិក្ស
  - ប្រជាជនរស់ដោយប្រឈមមុខ និងមនោគមវិជ្ជានៃសង្គ្រាមត្រជាក់ សឹកសង្គ្រាម ការទម្លាក់គ្រាប់បែកពីសហរដ្ឋអាមេរិក

- ប្រជាជនមួយចំនួនរត់ចូលក្នុងព្រៃតាមការអំពាវនាវរបស់សម្តេច នរោត្តម សីហនុ ឯខ្លះទៀតភៀសខ្លួនមកកាន់ទីក្រុងភ្នំពេញ រស់នៅដោយកង្វះអាហារ បាត់បង់ការងារ

- ខាងសេដ្ឋកិច្ច

រដ្ឋប្រហារធ្វើឲ្យសេដ្ឋកិច្ចកម្ពុជាជាប់គាំងដោយៈ

- ដីស្រែចម្ការទំនេរទុកទំនេរចោល ទិន្នផលធ្លាក់ចុះ
- រោងចក្រសហគ្រាសត្រូវបិទទ្វា
- ទំនិញឡើងថ្លៃ អតិផរណា

- ខាងនយោបាយ

- កម្ពុជាបាត់បង់កេរ្តិ៍ឈ្មោះ កិត្តិយសលើឆាកអន្តរជាតិ
- អស្ថិរភាពខាងនយោបាយធ្វើឲ្យប្រជាជនបាត់បង់ជំនឿលើអ្នកដឹកនាំ
- កម្ពុជាបាត់បង់ឯករាជ្យ អធិបតេយ្យ បូរណភាពទឹកដី
- មានការផ្លាស់ប្តូររបបនយោបាយ
- ជាការបើកផ្លូវឲ្យខ្មែរក្រហមឡើងកាន់អំណាច ដែលនាំឲ្យកម្ពុជាទៅរកការសម្លាប់រង្គាលក្នុងរបបប្រល័យពូជសាសន៍។

( មានចម្លើយត្រឹមត្រូវផ្សេងៗទៀត )

**១៥**.មូលហេតុអ្វីបានជាត្រូវកាត់ទោសមេដឹកនាំ កម្ពុជាប្រជាធិបតេយ្យ (ខ្មែរក្រហម)?

បានជាតុលាយកមេដឹកនាំកំពូលរបស់ខ្មែរក្រហម ដែលកាន់អំណាចនៅឆ្នាំ ១៩៧៥-១៩៧៩ ទៅកាត់ទោសព្រោះៈ

- មេដឹកនាំខ្មែរក្រហមទាំងនេះបានប្រព្រឹត្តអំពើឧក្រិដ្ឋកម្មក្នុងពេលកាន់អំណាចមានៈ
  - ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍
  - ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ
  - ឧក្រិដ្ឋកម្មសង្គ្រាម
  - ឧក្រិដ្ឋប្រឆាំងនិងអ្នកទទួលបានការការពារជាអន្តរជាតិ
  - ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាក្រុងហ្សឺណែវឆ្នាំ១៩៤៩
  - ការបំផ្លាញទ្រព្យសម្បត្តិវប្បធម៌របស់មនុស្សជាតិ
- តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមទាំងនេះដើម្បីៈ
  - ផ្តល់យុត្តិធម៌ ផ្តល់ភាពស្ងប់ចិត្ត ការផ្សះផ្សាវិបត្តផ្លូវចិត្ត ដល់ជនរងគ្រោះដែលរស់រានមានជីវិត

- ជាមេរៀន ជាគំរូដល់មេដឹកនាំជំនាន់ក្រោយកុំឲ្យត្រាប់តាម
- ដើម្បីទប់ស្កាត់កុំឲ្យរបបនេះកើតមានជាថ្មី
- ធ្វើការបង្រួបបង្រួមជាតិ ផ្សះផ្សាជាតិ
- ផ្តល់យុត្តិធម៌ឲ្យជនរងគ្រោះដែលបាត់បង់ជីវិត
- ជាការដាក់ទណ្ឌកម្មដល់អ្នកដែលបានប្រព្រឹត្តកុំឲ្យរួចខ្លួន

**១៦**.ពណ៌នាអំពីវិនាសកម្មនៅកម្ពុជាក្រោមរបបប្រល័យពូជសាសន៍កម្ពុជាប្រជាធិបតេយ្យនិងការស្តាបនាកម្ពុជាឡើងវិញ។

វិនាសកម្មនៅកម្ពុជា ក្រោមរបបប្រល័យពូជសាសន៍ កម្ពុជាប្រជាធិបតេយ្យ និងការស្តាបនាកម្ពុជាឡើងវិញ៖

- វិនាសកម្មក្រោមរបបប្រល័យពូជសាសន៍៖
  - សង្គម ៖ ជម្លៀសប្រជាជន សម្លាប់រង្គាល បង្អត់អាហារ ធ្វើការជាទម្ងន់ បំបិទសិទ្ធិសេរីភាព...
  - វប្បធម៌ ៖ បំបាត់សាលារៀន វត្តអារាម ជំនឿ សាសនា ទំនៀមទម្លាប់ ប្រពៃណី
  - ហេដ្ឋារចនាសម្ព័ន្ធ៖សាលារៀន មន្ទីរពេទ្យ ផ្លូវថ្នល់ ស្ពាន សំណង់ សាធារណៈរងការខូចខាត
  - សេដ្ឋកិច្ច ៖ បំបាត់ទីផ្សារ រូបិយវត្ថុ កម្មសិទ្ធិឯកជន ពាណិជ្ជកម្មក្នុង និងក្រៅប្រទេស
  - នយោបាយ ៖ អនុវត្តនយោបាយផ្តាច់ការ បំភិតបំភ័យ សម្រិតសម្រាំង សម្លាប់ និងផ្តាច់ទំនាក់ទំនងជាមួយប្រទេសមួយចំនួនលើពិភពលោក។
- ការស្តាបនាកម្ពុជាឡើងវិញ៖
  - បង្កើតក្រុមសាមគ្គីបង្កបង្កើនផល ដើម្បីជួយស្ត្រីមេម៉ាយ ចាស់ជរា ក្មេងកំព្រា...
  - បង្កើតរចនាសម្ព័ន្ធគ្រប់គ្រង
  - ស្តារសេដ្ឋកិច្ច កសិកម្ម ឧស្សាហកម្ម ពាណិជកម្ម
  - អប់រំ វប្បធម៌ បង្កើតសាលារៀនគ្រប់កម្រិតសិក្សា បង្កើតវត្តអារាម ជំនឿ សាសនា ប្រពៃណីទំនៀមទម្លាប់
  - ខាងនយោបាយ ស្តារមុខមាត់សេដ្ឋកិច្ចជាតិកម្ពុជាលើឆាកអន្តរជាតិ បង្រួបបង្រួមជាតិ ដែលឈានទៅដលការបញ្ចប់សង្គ្រាម ( ២៣ តុលា ១៩៩១ )

**១៧**.ហេតុអ្វីបានជាកម្ពុជារងនូវការបំផ្លិចបំផ្លាញក្នុងរបបខ្មែរក្រហម?

កម្ពុជារងការបំផ្លិចបំផ្លាញក្នុងរបបខ្មែរក្រហមព្រោះ៖

- ប្រកាន់យករបបផ្តាច់ការ ខ្មៅងងឹត
- ទទួលរងឥទ្ធិពលសង្គ្រាមត្រជាក់

- មេដឹកនាំមានចរឹតជាតិនិយមជ្រុល
- មនោគមវិជ្ជាជ្រុល
- ការប្រល័យពូជសាសន៍
- ជម្លៀសប្រជាជនចេញពីទីក្រុង និងទីប្រជុំជននានា
- បង្ខំប្រជាជនខ្មែរឲ្យធ្វើការជាទម្ងន់
- បង្អត់អាហារ ធ្វើទារុណកម្ម
- បំបិទសិទ្ធិសេរីភាព បំបាត់ជំនឿ សាសនា ប្រពៃណី ទំនៀមទម្លាប់ ការអប់រំ
- បង្កើតសហករណ៍កម្រិតខ្ពស់ទូទាំងប្រទេស លុបបំបាត់កម្មសិទ្ធិឯកជន
- ធ្វើវិសុទ្ធកម្ម។

( ទិដ្ឋភាពផ្សេងៗទៀត)

**១៨**.ចូរពណ៌នាពីកត្តាសំខាន់ៗដែលធ្វើឲ្យរបបកម្ពុជាប្រជាធិបតេយ្យ(១៩៧៥-១៩៧៩)ដួលរលំ។

កត្តាដែលធ្វើឲ្យរបបកម្ពុជាប្រជាធិបតេយ្យដួលរលំមាន៖

- ការស្អប់ខ្ពើមរបប ប៉ុល ពត របស់ប្រជាជនកម្ពុជា ព្រោះរបបនេះមាន៖
  - ធ្វើទារុណកម្ម និងការសម្លាប់ប្រជាជន
  - បង្ខំឲ្យមនុស្សធ្វើការជាទម្ងន់ ទ្រុឌទ្រោមសុខភាព និងបាក់កម្លាំង
  - កង្វះអាហារ កង្វះសម្លៀកបំពាក់ គ្មានថ្នាំសម្រាប់ព្យាបាល រងចាំតែសេចក្តីស្លាប់
  - បំបិទសិទ្ធិសេរីភាព ជំនឿសាសនា ប្រពៃណី ទំនៀមទម្លាប់
- ការសម្រិតសម្រាំងយកមនុស្សបដិវត្តន៍បរិសុទ្ធ ៖

  ការអនុវត្តនយោបាយសម្រិតសម្រាំងយកមនុស្សបដិវត្តន៍បរិសុទ្ធក្នុងចំណោមសមាជិកសំខាន់ៗនៃបក្សកុម្មុយនីស្តកម្ពុជាបានបណ្តាលឲ្យ៖
  - មានការចាប់ ការសួរចម្លើយ ការធ្វើទារុណកម្ម សម្លាប់កម្មាភិបាលគ្នាឯង
  - សមាជិកបក្សកុម្មុយនីស្តកម្ពុជា និងថ្នាក់ដឹកនាំបែកបាក់ផ្ទៃក្នុង
- ការធ្វើសង្គ្រាមជាមួយវៀតណាម៖

  ចាប់ពីឆ្នាំ ១៩៧៥ កម្ពុជាប្រជាធិបតេយ្យ ចាប់ផ្តើមបង្កជម្លោះតាមព្រំដែន ដោយពុំប្រមាណកម្លាំងរបស់ខ្លួន (កងទ័ពខ្មែរក្រហមមានចំនួនតិច អាវុធពុំទំនើប យុទ្ធសាស្ត្រខ្សោយ ឯកងទ័ពវៀតណាមមានចំនួនច្រើន អាវុធទំនើប យុទ្ធសាស្ត្រខ្លាំង)

❖ ការបង្កើតរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា៖

- នៅថ្ងៃទី ២ ខែធ្នូ ឆ្នាំ១៩៧៨ រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាបានបង្កើតឡើងក្នុងបំណងរំដោះប្រទេសពី របបកម្ពុជាប្រជាធិបតេយ្យដែលជារបបប្រល័យពូជសាសន៍
- ដោយមានការគាំទ្រពីកងទ័ពវៀតណាម រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាបានបើកការវាយប្រហារលើកងទ័ពខ្មែរក្រហមនាថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៧៨ និងទទួលបានជោគជ័យជម្នះនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩។

**១៩**.មូលហេតុអ្វីបានជារបបប្រល័យពូជសាសន៍ កម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) សម្លាប់មនុស្ស? តើមានផលវិបាកអ្វីខ្លះសម្រាប់កម្ពុជា?

មូលហេតុនៃការសម្លាប់មនុស្សក្នុងរបបប្រល័យពូជសាសន៍កម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងផលវិបាកដល់កម្ពុជា៖

❖ **មូលហេតុ ៖**

- ការអនុវត្តគោលនយោបាយ ៨ប្រការរបស់ខ្មែរក្រហម
- ប្រកាន់បដិវត្តន៍កុម្មុយនីស្ត ដែលតម្រូវឲ្យការកម្ទេច
- ការអនុវត្តនយោបាយ " មហាលោតផ្លោះ មហាអស្ចារ្យ " ដើម្បីសម្រេចគោលដៅឲ្យបានឆាប់រហ័ស ( ផែនការ៤ឆ្នាំ )
- គំនិតស្នេហាជាតិនិយមជ្រុល ងងឹតងងុល ដោយតម្រូវឲ្យជឿជាក់តែលើអង្គការមួយ បើពុំនោះទេត្រូវតែសម្លាប់ចោល
- ការអប់រំបំពាក់កំហឹងវណ្ណៈដល់កម្មាភិបាលខ្មែរក្រហម តាំងពីមុនឆ្នាំ១៩៧៥
- នយោបាយវិមជ្ឈការសិទ្ធិអំណាច កាប់សម្លាប់មនុស្សដល់កម្មាភិបាលថ្នាក់ទាបដែលភាគច្រើនជាមនុស្សមានការសិក្សាតិចតួច ឬល្ងង់ខ្លៅ និងក្លាយជាអ្នកដឹកនាំតាមមូលដ្ឋានដោយខ្វះការត្រួតពិនិត្យពីថ្នាក់លើ
- គោលនយោបាយបោសសម្អាត សម្រិតសម្រាំង យកមនុស្សបដិវត្តន៍បរិសុទ្ធ
- គំនុំគំគួនផ្សេងៗ ការសងសឹក...
- ការធ្វើសង្គ្រាមប្រឆាំងវៀតណាម...

❖ ផលវិបាក ៖

របបកម្ពុជាប្រជាធិបតេយ្យបង្កផលវិបាកដល់ប្រទេសជាតិមានដូចជា៖

- បាត់បង់កិត្តិយសជាតិ និងកិត្យានុភាពលើឆាកអន្តរជាតិ
- ដាច់និរន្តរភាពក្នុងការអភិវឌ្ឍជាតិ

- សេដ្ឋកិច្ចជាតិរលត់រលាយ
- ប្រព័ន្ធអប់រំត្រូវបានបំផ្លាញទាំងស្រុង បាត់បង់ធនធានមនុស្ស
- បន្សល់ទុកស្ត្រីមេម៉ាយ ក្មេងកំព្រា ជនបាក់កម្លាំង
- ប្រជាជនរាប់សែននាក់ រត់ចាកចោលប្រទេស
- បង្កជាវិបត្តិផ្លូវចិត្ត
- ហេដ្ឋារចនាសម្ព័ន្ធត្រូវបំផ្លាញ
- វប្បធម៌ សាសនា និងជំនឿត្រូវបំផ្លាញចោល
- សិទ្ធិ សេរីភាព កម្មសិទ្ធិឯកជន តម្រូវការជាមូលដ្ឋានត្រូវបានដកហូត...

( មតិផ្សេងៗទៀត )

**២០.ពណ៌នាពីនយោបាយបង្រួបបង្រួមជាតិ ដែលបាននាំមកនូវសន្តិភាពនៅកម្ពុជា។**

ការខិតខំចរចារកសន្តិភាព និងការបង្រួបបង្រួមជាតិនៅកម្ពុជា៖

- ខែវិច្ឆិកា ១៩៨៤ ប្រទេសបារាំងរៀបចំគម្រោងជំនួបរវាងសម្តេច នរោត្តម សីហនុ និងតំណាងសាធារណរដ្ឋប្រជាមានិតកម្ពុជា
- ឆ្នាំ១៩៨៥ សភាពការណ៍នយោបាយនៅអាស៊ី អនុគ្រោះដល់ការចរចាររកសន្តិភាពនៅកម្ពុជា
- ខែកក្កដា ឆ្នាំ១៩៨៧ ទស្សនកិច្ចជាផ្លូវការរបស់មន្ត្រីការប្រទេសឥណ្ឌូនេស៊ី នៅវៀតណាម ពិភាក្សាលើរូបមន្តនៃការជួបគ្នារវាងគូវិវាទខ្មែរទាំងអស់ជាពីរដំណាក់កាលគឺ
  - ការជួបគ្នារវាងបណ្តាភាគីខ្មែរបដិបក្ខទាំងពីរ
  - ការជួបគ្នារវាងបណ្តាភាគីខ្មែរ និងប្រទេសពាក់ព័ន្ធដើម្បីដោះស្រាយនយោបាយនៅកម្ពុជា
- ឆ្នាំ ១៩៨៧ ជំនួបកំពូលរវាងអាមេរិកនិងសហភាពសូវៀត ធ្វើឲ្យសភាពការណ៍នៅកម្ពុជាធូស្រាល
- ខែសីហា និងខែតុលា ឆ្នាំ១៩៨៧ រដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជាដាក់សំណើសន្តិភាព និងបង្រួបបង្រួមជាតិទៅភាគីសម្តេច នរោត្តម សីហនុ
- ថ្ងៃទី២ ខែធ្នូ ឆ្នាំ១៩៨៧ ជួបលើកទី១រវាងសម្តេចនរោត្តម សីហនុ និងលោក ហ៊ុន សែន
- ជំនួបលើកទី២ រវាងសម្តេចនរោត្តម សីហនុ និងលោក ហ៊ុន សែន ថ្ងៃទី២១-២២ ខែមករា ១៩៨៨ នៅប្រទេសបារាំង ជំនួបលើកទី៣-៤-៥ សម្តេចនរោត្តម សីហនុ បានលុបចោល
- វេទិកាសម្តេច នរោត្តម សីហនុ និងឯកឧត្តម ហ៊ុន សែន ប្រព្រឹត្តទៅនៅទីក្រុងប៉ារីស ហ្សាកាតា និងប៉ាតាយ៉ា ដើម្បីដោះស្រាយនយោបាយកម្ពុជា
- ថ្ងៃទី ២៦ កញ្ញា ១៩៨៩ កងទ័ពវៀតណាមដកចេញពីកម្ពុជា

- ថ្ងៃទី៣០ កក្កដា ដល់៣០ សីហា ១៩៨៩ នៅទីក្រុងប៉ារីស សហប្រធាន (ឥណ្ឌូនេស៊ី+បារាំង) បានបង្កើតក្រុមប្រឹក្សាជាតិជាន់ខ្ពស់ (NSN) នៅថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩០ ដែលមានសមាជិក១២រូប (៦រូបមកពីភាគីរដ្ឋកម្ពុជា និង៦រូបមកពីសម្ព័ន្ធត្រីភាគី) ក្រុមប្រឹក្សាជាតិជាន់ខ្ពស់ប្រជុំនៅទីក្រុងបាងកក នៅប្រទេសបារាំង ក្រុងញ៉ូវយ៉ក ហ្សាកាតា យ៉ាតាយ៉ា និងប៉េកាំង ដើម្បីដោះស្រាយ បញ្ចប់សង្គ្រាមនៅកម្ពុជា
- ថ្ងៃទី២៣-២៤ ខែមិថុនា ឆ្នាំ១៩៩១ ភាគីទាំង៤ បានស្រុះស្រួលគ្នាដោះស្រាយបញ្ហាជាតិ
- ថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ សន្និសីទក្រុងប៉ារីស បានព្រមព្រៀងចុះហត្ថលេខាលើ សន្ធិសញ្ញាសន្តិភាព ហើយវិបត្តិនយោបាយនៅកម្ពុជាត្រូវបានបញ្ចប់
- ថ្ងៃទី២៣-២៨ ខែឧសភា ឆ្នាំ១៩៩៣ ការបោះឆ្នោតដោយសេរី និងយុត្តិធម៌បានរៀបចំឡើងដោយ អ៊ុនតាក់
    - នយោបាយ ឈ្នះ-ឈ្នះរបស់សម្តេច ហ៊ុន សែន
- ឆ្នាំ១៩៩៨ សមាហរណកម្ម កងកម្លាំងខ្មែរក្រហម ឲ្យចូលមករួមរស់ជាមួយរដ្ឋាភិបាលដែលនាំសន្តិភាពពេញលេញមកឲ្យកម្ពុជា។

( ចម្លើយត្រឹមត្រូវផ្សេងៗទៀត )

**២១**.ពណ៌នាពីការកសាងជាតិឡើងវិញក្រោយរបបខ្មែរក្រហមពីឆ្នាំ១៩៧៩-១៩៩០។

ការកសាងជាតិឡើងវិញ ក្រោយរបបខ្មែរក្រហមពីឆ្នាំ១៩៧០-១៩៩០៖

- ❖ វិស័យនយោបាយ
    - រំដោះប្រជាជនរួចផុតពីរបបប្រល័យពូជសាសន៍ ប៉ុល ពត ទាំងស្រុង
    - ទប់ស្កាត់ការវិលត្រឡប់នៃរបបប្រល័យពូជសាសន៍ ប៉ុល ពត
    - ទប់ស្កាត់អំពើអសកម្មក្នុងសង្គម ការជួញដូរមនុស្ស អាវុធ គ្រឿងញៀន
    - លើកកម្ពស់លទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស
    - ធ្វើកំណែទម្រង់រដ្ឋធម្មនុញ្ញ (វិសោធនកម្មរដ្ឋធម្មនុញ្ញ)
    - អនុវត្តនយោបាយបង្រួបបង្រួមជាតិ
- ❖ វិស័យសេដ្ឋកិច្ច ៖ រដ្ឋាភិបាលបានស្ថាបនាសេដ្ឋកិច្ចដោយ៖
    - បង្កើតក្រុមសាមគ្គីបង្កបង្កើនផល ដើម្បីជួយដល់ស្ត្រីមេម៉ាយ ក្មេងកំព្រា ចាស់ជរា...
    - ឆ្នាំ១៩៨០ បោះពុម្ពក្រដាសប្រាក់ឲ្យចាយវាយទូទាំងប្រទេស
    - ឆ្នាំ១៩៨៣-១៩៨៦ ប្តូរពីក្រុមសាមគ្គីបង្កបង្កើនផល ទៅជាម្ចាស់ការទាំងស្រុងដោយធ្វើការបែងចែកដីធ្លី និងឈានទៅរកកម្មសិទ្ធិឯកជន

- អនុវត្តមុខព្រួញទាំង៤នៃសេដ្ឋកិច្ច
- កសាងហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ច ( ផ្លូវថ្នល់ ស្ពាន កំពង់ផែ...)
- ពង្រឹងកិច្ចសហប្រត្តិការសេដ្ឋកិច្ចជាមួយប្រទេសតំបន់ និងពិភពលោក
- ពង្រឹងសន្តិភាព សុវត្ថិភាព និងសណ្តាប់ធ្នាប់សង្គមដើម្បីទាក់ទាញវិនិយោគទុនពីបរទេស
- បង្កើតសេដ្ឋកិច្ចទីផ្សារសេរី និងជំរុញការអភិវឌ្ឍធនធានមនុស្ស

❖ ការស្តាបនាសង្គម

- វិស័យអប់រំ ៖ ប្រព័ន្ធអប់រំត្រូវបានស្តាឡើងវិញ ដោយបើកទ្វារសាលារៀនគ្រប់ភូមិសិក្សា ដល់ឧត្តមសិក្សាទទួលសិស្សឲ្យចូលរៀន តាំងពីទីក្រុងដល់ជនបទ ធ្វើការជ្រើសរើស និងបណ្តុះបណ្តាលគ្រូបង្រៀន ជំរុញនិងបំផុសចលនាអក្ខរកម្ម បំពេញវិជ្ជា អនុវត្តនយោបាយ " អ្នកចេះច្រើនបង្រៀនអ្នកចេះតិច អ្នកចេះតិចបង្រៀនអ្នកមិនចេះ " បញ្ជូនសិស្សនិស្សិត ទៅសិក្សានៅបរទេស និងអញ្ជើញគ្រូបរទេសមកបង្ហាត់បង្រៀនខ្មែរនៅក្នុងប្រទេស...
- វិស័យវប្បធម៌ ៖ បើកសេរីភាពដល់ជំនឿ សាសនា ប្រពៃណី ទំនៀមទម្លាប់ បើកទ្វារសាលាវិចិត្រសិល្បៈ និងប្រមូលផ្តុំសិល្បករ
- វិស័យសង្គមកិច្ច៖ បង្កើតមជ្ឈមណ្ឌលកុមារកំព្រា បង្កើតសាលាបណ្តុះបណ្តាលវិជ្ជាជីវៈសម្រាប់ជនពិការ និងស្ត្រីមេម៉ាយ បង្កើតច្បាប់ការពារកម្មសិទ្ធឯកជន (១៩៨៧)
- វិស័យសុខាភិបាល៖ បើកទ្វាមន្ទីពេទ្យទទួលពិនិត្យ និងព្យាបាលជំងឺ បើកទ្វាសាលាបណ្តុះបណ្តាលពេទ្យ មានមហាវិទ្យាល័យវិជ្ជាសាស្ត្រ ឱសថសាស្ត្រ ទន្តសាស្ត្រ។

**២៣**.ចូរពណ៌នាពីចលនាតស៊ូ ដើម្បីរំដោះប្រទេសកម្ពុជាពីរបបប្រល័យពូជសាសន៍ " កម្ពុជាប្រជាធិបតេយ្យ " (១៩៧៥-១៩៧៩)។

ចលនាតស៊ូដើម្បីរំដោះប្រទេសកម្ពុជាពីរបបប្រល័យពូជសាសន៍ " កម្ពុជាប្រជាធិបតេយ្យ"
ឆ្នាំ១៩៧៥-១៩៧៩៖

- ខែមករា ឆ្នាំ១៩៧៦ លោក **ហ៊ូ នឹម** ចេញមុខប្រឆាំងនិង **ប៉ុល ពត**
- ខែមីនា ឆ្នាំ១៩៧៦ ប្រជាជននៅចម្ការហ្លួង និងខេត្តសៀមរាប ទាមទារឲ្យតម្លើងកម្រិតជីវភាព និងឲ្យគ្រួសាររស់នៅជួបជុំគ្នា
- ឆ្នាំ១៩៧៧ ប្រជាជននៅសៀមរាប បាត់ដំបង កំពង់ធំ កំពង់ឆ្នាំង មណ្ឌលគិរី ចម្ការហ្លួង បះបោរប្រឆាំង **ប៉ុល ពត**
- ថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៧៧ លោក ហ៊ុន សែន បានភៀសខ្លួនទៅប្រទេសវៀតណាមដើម្បីស្វែងរកការគាំទ្រ និងបង្កើតកម្លាំងប្រឆាំងខ្មែរក្រហម

- ថ្ងៃទី២ ខែធ្នូ ឆ្នាំ១៩៧៨ មហាសន្និបាត បានសម្រេចបង្កើត "រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុ-ជា" ដែលដឹកនាំដោយលោក **ហេង សំរិន**
- ដោយមានជំនួយកងទ័ពវៀតណាម និងការចូលរួមពីប្រជាជនកម្ពុជា រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា បានវាយលើកម្លាំងកងទ័ពខ្មែរក្រហមតែរយៈពេលបីសប្តាហ៍រំដោះប្រជាជនបានស្ទើទាំងស្រុងទូទាំងប្រទេស
- ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ប្រជាជនកម្ពុជាត្រូវបានរំដោះឲ្យរួចចាកផុតពីរបបប្រល័យពូជសាសន៍ ប៉ុល ពត ។

**២៤.** ចូរពណ៌នាពីរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា។

ពណ៌នាពីរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា៖

របបសាធារណរដ្ឋប្រជាមានិតកម្ពុជា ( ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៨៩) មានកិច្ចការចាំបាច់ពីរគឺ ការកសាងសន្តិភាព និងការស្តាបនាជាតិឡើងវិញ

❖ អង្គការគ្រប់គ្រងសំខាន់ៗនៃរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជា

របបសាធារណរដ្ឋប្រជាមានិតកម្ពុជាគ្រប់គ្រងដោយគណបក្សតែមួយគឺគណបក្សប្រជាជនបដិវត្តន៍កម្ពុជា និងអង្គការគ្រប់គ្រងសំខាន់ៗ៤គឺ៖

- គណបក្សប្រជាជនបក្សដិវត្តន៍កម្ពុជា
- ក្រុមប្រឹក្សាប្រជាជនបដិវត្តន៍ ឬក្រុមប្រឹក្សារដ្ឋមន្ត្រី
- ក្រុមប្រឹក្សារដ្ឋ
- រដ្ឋសភាជាតិ

❖ រដ្ឋអំណាចខ្មែរ

- ដំណាក់កាលដំបូង៖ ក្រសួងសំខាន់ៗគ្រប់គ្រងដោយមនុស្សពីរក្រុមគឺ អ្នកតស៊ូចាស់ៗ នៅភូមិភាគបូព៌ា ( សមមិត្ត ហេង សំរិន ,ជាស៊ីម ,ហ៊ុន សែន) និងអ្នករៀននៅវៀតណាមក្រោយសន្និសីទហ្សឺណែវ ឆ្នាំ១៩៥៤ ( សមមិត្ត ប៉ែន សុវណ្ណ , ចាន់ ស៊ី )
- ដំណាក់កាលបន្ទាប់ ៖ ពេលសន្តិសុខប្រទេសមានលំនិង រដ្ឋាភិបាល ជ្រើសរើសអ្នកមានសមត្ថភាពឲ្យបម្រើក្នុងក្បាលម៉ាស៊ីនដឹកនាំរដ្ឋ។

❖ អ្នកជំនាញការ និងកងទ័ពវៀតណាម

- អ្នកជំនាញការវៀតណាមអមរដ្ឋខ្មែរតាំងពីថ្នាក់ក្រសួងដល់ថ្នាក់មូលដ្ឋានដើម្បីជួយពង្រឹងរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជា

- កងទ័ពវៀតណាមនៅពាសពេញផ្ទៃប្រទេសដើម្បីជួយទប់ស្កាត់ការវិលត្រឡប់មកវិញនៃរបបប្រល័យពូជសាសន៍

❖ កិច្ចការពារជាតិ

ដើម្បីទប់ស្កាត់ការវិលត្រឡប់មកវិញរបបខ្មែរក្រហម រដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជាបានចាត់វិធានការដូចតទៅ៖

- បង្កើតកងសេនាជនភូមិ បង្កើតក្រុមស្វ័យការពារ ក្រុមឃាមកាម ធ្វើការជ្រើសរើសកងទ័ព បង្កើតកាតព្វកិច្ចយោធា ធ្វើការហ្វឹកហាត់ក្បួនយោធាដល់សិស្សនិស្សិត មុនចូលរៀន
- លើកទ័ពវាយលុកលើខ្មែរក្រហមនារដូវប្រាំង និងគ្រប់គ្រងតំបន់តាមព្រំដែន
- បង្កើតកិច្ចការពារ នៅតាមព្រំដែនកម្ពុជា-ថៃ ដោយអនុវត្តផែនការ"ក៥"
- ស្វែងរកការបញ្ចប់សង្គ្រាម។

❖ ការកសាងជាតិរដ្ឋាភិបាលបានរៀបចំកសាងជាតិ

- ការស្តាបនាសេដ្ឋកិច្ច៖ បញ្ហាបន្ទាន់គឺស្បៀង
  - អំពាវនាវជំនួយពីសហគមន៍អន្តរជាតិ
  - បង្កើនក្រុមសាមគ្គីបង្កបង្កើនផល
  - ឆ្នាំ១៩៨០ បោះពុម្ពក្រដាសប្រាក់ឲ្យចាយវាយទូទាំងប្រទេស
  - ឆ្នាំ១៩៨៣-១៩៨៦ ប្តូរពីក្រុមសាមគ្គីបង្កបង្កើនផលទៅជាម្ចាស់ការទាំងស្រុងដោយធ្វើការបែងចែកដីធ្លី និងឈានទៅរកកម្មសិទ្ធិឯកជន
  - អនុវត្តមុខព្រួញទាំង៤នៃសេដ្ឋកិច្ច
- ការស្តាបនាសង្គម
  - វិស័យអប់រំ៖ ប្រព័ន្ធអប់រំត្រូវបានស្តារឡើងវិញដោយ៖
    - បើកទ្វារសាលាទទួលសិស្ស និស្សិត ឲ្យចូលរៀន
    - ធ្វើការជ្រើសរើស និងបណ្តុះបណ្តាលគ្រូ
    - ជំរុញចលនាអក្ខរកម្ម និងបំពេញវិជ្ជា
    - អនុវត្តនយោបាយ " អ្នកចេះច្រើនបង្រៀនអ្នកចេះតិច អ្នកចេះតិចបង្រៀនអ្នកមិនចេះសោះ"
    - បញ្ជូននិស្សិតទៅសិក្សានៅបរទេស
  - វិស័យវប្បធម៌
    - បើកសេរីភាពដល់ ជំនឿ សាសនា ប្រពៃណីទំនៀមទម្លាប់

- បើកទ្វារសាលាវិចិត្រសិល្បៈនិងប្រមូលផ្តុំសិល្បករ

- វិស័យសង្គមកិច្ច ៖ បង្កើតមជ្ឈមណ្ឌលកុមារកំព្រា បង្កើតសាលាបណ្តុះបណ្តាលវិជ្ជាជីវៈសម្រាប់ជនពិការ និងស្ត្រីមេម៉ាយ បង្កើតច្បាប់ការពារកម្មសិទ្ធិឯកជន
- វិស័យសុខាភិបាល ៖ បើកទ្វារមន្ទីរពេទ្យទទួលពិនិត្យ និងព្យាបាលជំងឺ បើកទ្វារសាលាបណ្តុះបណ្តាលពេទ្យ មានមហាវិទ្យាល័យវេជ្ជសាស្ត្រ ឱសថសាស្ត្រ ទន្តសាស្ត្រ។

( មានចម្លើយត្រឹមត្រូវផ្សេងទៀត)

**២៥**.តើសម្តេច នរោត្តម សីហនុ និងសម្តេច ហ៊ុន សែន មានតួនាទីអ្វីខ្លះក្នុងការបញ្ចប់សង្គ្រាមនៅកម្ពុជា?

តួនាទីរបស់សម្តេច នរោត្តម សីហនុ និងសម្តេច ហ៊ុន សែន ក្នុងការបញ្ចប់សង្គ្រាមនៅកម្ពុជាមាន៖

- **សម្តេច នរោត្តម សីហនុ**
  - ជាតំណាងសម្ព័ន្ធត្រីភាគី(ខ្មែរក្រហម ហ៊្វុនស៊ិនប៉ិច រណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ)
  - ជាអ្នកផ្តើមគំនិតឲ្យមានការចរចាបញ្ចប់សង្គ្រាមនៅកម្ពុជា
  - ជាប្រធានក្រុមប្រឹក្សាជាន់ខ្ពស់ (SNC)
  - ជាម្ចាស់ហត្ថលេខីនៃកិច្ចព្រមព្រៀងសន្តិភាពក្រុងប៉ារីសថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១
  - ជាបិតាបង្រួបបង្រួមជាតិ ជាអ្នកផ្សះផ្សាជាតិ ក្នុងវិវាទនៃការដណ្តើមឧត្តមភាពគ្នារវាងគណបក្សហ៊្វុនស៊ិនប៉ិច និងគណបក្សប្រជាជនកម្ពុជាក្រោយការបោះឆ្នោត(១៩៩៣)ដោយបង្កើតឲ្យមានរដ្ឋាភិបាលចម្រុះ ដែលនាំមកនូវសន្តិភាពជូនប្រទេសជាតិ។
- **សម្តេច ហ៊ុន សែន**
  - ជាតំណាងរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជា និងរដ្ឋកម្ពុជា
  - ជាអ្នកផ្តើមគំនិតឲ្យមានការចរចាបញ្ចប់សង្គ្រាមនៅកម្ពុជា
  - ជាម្ចាស់ហត្ថលេខីនៃកិច្ចព្រមព្រៀងសន្តិភាពនៅក្រុងប៉ារីសថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១
  - ជាអ្នកធានាអះអាងសណ្តាប់ធ្នាប់ សន្តិសុខ ក្នុងការបោះឆ្នោតឆ្នាំ១៩៩៣
  - ជាអ្នកបង្រួបបង្រួមជាតិ ផ្សះផ្សាជាតិដោយធ្វើសមាហរណកម្មកងកម្លាំងខ្មែរក្រហមឲ្យចូលមករួមរស់ជាមួយរាជរដ្ឋាភិបាល តាមរយៈការអនុវត្តនយោបាយឈ្នះ-ឈ្នះ ដែលនាំសន្តិភាពពេញលេញជូនជាតិមាតុភូមិនាឆ្នាំ១៩៩៨ (២៩ ធ្នូ ១៩៩៨)។

**២៦**.តើការដាក់ប្រាសាទព្រះវិហារចូលក្នុងបញ្ជីបេតិកភណ្ឌពិភពលោកមានអត្ថន័យដូចម្ដេចសម្រាប់កម្ពុជា?

ការដាក់ប្រាសាទព្រះវិហារចូលក្នុងបញ្ជីបេតិកភណ្ឌពិភពលោកមានអត្ថន័យសម្រាប់កម្ពុជាដូចតទៅៈ

- ជាមោទកភាពជាតិខ្មែរ
- រក្សាបូរណភាពទឹកដី
- បង្ហាញពីអត្តសញ្ញាណខ្មែរលើឆាកអន្តរជាតិ
- បង្ហាញពីភាពប៉ិនប្រសប់ ការច្នៃប្រឌិត ទេពកោសល្យដ៏ល្អឯករបស់បុព្វបុរសខ្មែរ ដែលផ្សារភ្ជាប់ទៅនិងអាទិទេព
- បង្ហាញពីភាពសំបូរបែបនៃរចនាបថ ស្ថាបត្យកម្មរបស់បុព្វបុរសខ្មែរ
- បង្ហាញសារជាថ្មីថាសម្បត្តិវប្បធម៌ទាំងនេះពិតជាមរត៌កប្រវត្តិសាស្ត្ររបស់ដូនតាខ្មែរ
- បង្ហាញពីវិសាលភាពទឹកដីខ្មែរ និងអំណាចព្រះរាជាក្នុងសម័យអង្គរ
- ទទួលបាននូវកិច្ចការពារពីសំណាក់សមាគមន៍អន្តរជាតិ
- ទទួលបានមូលនិធិ បច្ចេកទេសក្នុងការ ជួសជុល អភិរក្ស ថែរក្សាសម្បត្តិវប្បធម៌មនុស្សជាតិ
- កំណើនភ្ញៀវទេសចរ ដែលបង្កើនការងារនិងប្រាក់ចំណូលដល់ប្រជាជន
- កំណើនសេដ្ឋកិច្ច តាមរយៈកំណើនភ្ញៀវទេសចរ
- បណ្ដុះមនសិការស្នេហាជាតិ ស្រឡាញ់ ការពារ ថែរក្សាសម្បត្តិវប្បធម៌របស់មនុស្សជាតិ។

( ទិដ្ឋភាពផ្សេងៗទៀត)។

**២៧**.ចូរពណ៌នាពីគោលនយោបាយឈ្នះ-ឈ្នះរបស់សម្ដេច ហ៊ុន សែន ក្នុងការបញ្ចប់សង្គ្រាម នៅកម្ពុជា?

គោលនយោបាយឈ្នះ-ឈ្នះរបស់សម្ដេច ហ៊ុន សែន ក្នុងការបញ្ចប់សង្គ្រាមនៅកម្ពុជាៈ

- វិស័យនយោបាយៈ
  - ឆ្នាំ ១៩៩៨ សមាហរណកម្មកងទ័ពខ្មែរក្រហម ជាមួយកងទ័ពរាជរដ្ឋាភិបាលធ្វើឲ្យកងទ័ពមានការឯកភាពដើម្បីស្ថានិងកសាងប្រទេសជាតិ
  - ក្រោយពីកងកម្លាំងខ្មែរក្រហមដួលរលំ នៅតាមព្រំដែនមានសុវត្ថិភាព និងមានការអភិវឌ្ឍ
  - កម្ទេចអង្គការចាត់តាំងខ្មែរក្រហម
  - មាតុភូមិនិវត្តន៍របស់ជនភៀសខ្លួនតាមព្រំដែន
  - បែងចែកដីធ្លី កាន់កាប់ជាកម្មសិទ្ធិដល់បងប្អូនភៀសខ្លួន (អតីតខ្មែរក្រហម)
  - បងប្អូនខ្មែរក្រហមទទួលបានតួនាទី និងបុណ្យសក្តិដែលធ្លាប់មានពីមុន

- ❖ វិស័យសង្គម៖
  - ឆ្នាំ ១៩៩៨ មកដល់បច្ចុប្បន្ន ប្រទេសកម្ពុជាមានសុវត្ថិភាព និងសន្តិភាពពេញលេញ
  - ធ្វើឲ្យមានឯកភាពជាតិ និងការបង្រួបបង្រួមជាតិ
  - ធ្វើឲ្យមានសមិទ្ធផលច្រើន
- ❖ វិស័យសេដ្ឋកិច្ច ៖ កំណើនទិន្នផលកសិកម្ម ឧស្សាហកម្ម កំណើនអ្នកវិនិយោគ កំណើនភ្ញៀវទេសចរ មានទំនាក់ទំនងទីផ្សារក្នុងតំបន់ និងក្រៅតំបន់
- ❖ គមនាគមន៍ ៖ ការកសាងផ្លូវថ្នល់ ផ្លូវដែក ស្ពាន កំពង់ផែ អាកាសយានដ្ឋាន
- ❖ វិស័យអប់រំ ៖ កំណែទម្រង់ស៊ីជម្រៅលើវិស័យអប់រំ សាងសង់សាលារៀន បណ្តុះបណ្តាលធនធានមនុស្ស...
- ❖ សាសនា ៖ សុខដុមនីយកម្មខាងសាសនា
- ❖ សុខាភិបាល ៖ សាងសង់មន្ទីរពេទ្យ មណ្ឌលសុខភាព

(ទិដ្ឋភាពផ្សេងទៀត)

**២៨**.ចូរវិភាគពីព្រះរាជាណាចក្រកម្ពុជាទី២ និងការកសាងកម្ពុជាឡើងវិញ។

វិភាគពីព្រះរាជាណាចក្រកម្ពុជាទី២ និងការកសាងកម្ពុជាឡើងវិញ

- ❖ **ព្រះរាជាណាចក្រកម្ពុជាទី២**
  - កើតនៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ ដែលមានព្រះមហាក្សត្រសោយរាជ្យ
  - មានរដ្ឋធម្មនុញ្ញថ្មី សេរីពហុក្ស
  - មានរដ្ឋាភិបាលស្របច្បាប់មួយ
  - ព្រះរាជាណាចក្រកម្ពុជាទី២ កើតឡើងតាមរយៈការបោះឆ្នោតនៅថ្ងៃទី ២៣-២៨ ខែឧសភា ឆ្នាំ ១៩៩៣ រៀបចំដោយអង្គការសហប្រជាជាតិ ដែលនាំឲ្យមានការរៀបចំរដ្ឋាភិបាល ដោយសម្តេច នរោត្តម រណឫទ្ធិ និងសម្តេច ហ៊ុន សែន ជានាយករដ្ឋមន្ត្រី
  - ព្រះរាជាណាចក្រកម្ពុជាទី២ គឺចាប់ពីឆ្នាំ១៩៩៣ រហូតដល់បច្ចុប្បន្ន
  - ព្រះរាជាណាចក្រកម្ពុជាទី២ បានរៀបចំការបោះឆ្នោតជាសកលដោយសេរីក្នុងការជ្រើសរើសតំណាងរាស្ត្រ
- ❖ ការស្តាបនាកម្ពុជាឡើងវិញ
  - វិស័យនយោបាយ ៖ ធ្វើកំណែទម្រង់រដ្ឋាភិបាលសាធារណៈ កងទ័ពនគរបាលជាតិ សមភាពយេនឌ័រ

- វិស័យសេដ្ឋកិច្ច
  - ស្តារវិស័យកសិកម្ម ឧស្សាហកម្ម ពាណិជ្ជកម្ម
  - បង្កើតឲ្យមានប្រព័ន្ធសេដ្ឋកិច្ចទីផ្សារ ផ្តល់កម្មសិទ្ធឯកជន
  - ធ្វើកំណែទម្រង់ហេដ្ឋារចនាសម្ព័ន្ធជាតិ
- វិស័យអប់រំ វប្បធម៌ ៖ បង្កើតសាលារៀនគ្រប់កម្រិត វត្តអារាម សេរីភាព ខាងជំនឿ សាសនា
- វិស័យសង្គម ៖ ផ្តល់សេរីភាពដល់ប្រជាពលរដ្ឋ

(ទិដ្ឋភាពផ្សេងៗទៀត)

**២៩**. មូលហេតុអ្វីបានជាគេចាត់ទុកថា សម្តេច នរោត្តម សីហនុ និងសម្តេច ហ៊ុន សែន ជាបិតាសន្តិភាពនៅកម្ពុជា?

បានជាគេចាត់ទុកថា សម្តេចនរោត្តម សីហនុ និងសម្តេច ហ៊ុន សែន ជាបិតាសន្តិភាពនៅកម្ពុជាព្រោះ

- **សម្តេច នរោត្តម សីហនុ**
  - ជាអ្នកផ្តើមគំនិតឲ្យមានការចរចារកសន្តិភាព
  - ជាប្រធានក្រុមប្រឹក្សាជាន់ខ្ពស់ (SNC)
  - ជាអ្នកចុះហត្ថលេខាលើកិច្ចព្រមព្រៀងសន្តិភាពក្រុងប៉ារីស ( ២៣ តុលា ១៩៩១ )
  - ជាអ្នកបង្រួបបង្រួមជាតិ ជាអ្នកផ្សះផ្សាជាតិ ដោយធ្វើការផ្សះផ្សាវិបត្តិក្រោយបោះឆ្នោតឆ្នាំ ១៩៩៣ ដែលកើតចេញពីការដណ្តើមឥទ្ធិពលគ្នារវាងគណបក្សហ្វ៊ុនស៊ិនប៉ិច និងគណបក្សប្រជាជនកម្ពុជា បង្កើតបានជារដ្ឋាភិបាលចម្រុះ
  - ជាអ្នកផ្សះផ្សារាល់វិបត្តិនយោបាយក្រោយការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រឆ្នាំ១៩៩៨ ឆ្នាំ២០០៣...។

(មតិផ្សេងៗទៀត)

- **សម្តេច ហ៊ុន សែន**
  - ជាអ្នកផ្តើមគំនិតឲ្យមានការចរចាបញ្ចប់រកសន្តិភាព
  - ជាអ្នកចុះហត្ថលេខាលើកិច្ចព្រមព្រៀងសន្តិភាពនៅក្រុងប៉ារីស ( ២៣ តុលា ១៩៩១)
  - ជាអ្នកធានាអះអាងសណ្តាប់ធ្នាប់ សន្តិសុខ ក្នុងការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រថ្ងៃទី ២៣-២៨ ខែឧសភា ឆ្នាំ១៩៩៣
  - ជាអ្នកផ្សះផ្សាវិបត្តិក្រោយការបោះឆ្នោតឆ្នាំ១៩៩៣ ឆ្នាំ១៩៩៨ ឆ្នាំ២០០៣ ឆ្នាំ២០០៨ និងឆ្នាំ២០១៣

- ជាអ្នកបញ្ចប់សង្គ្រាមស៊ីវិលទាំងស្រុងនៅកម្ពុជា ដោយអនុវត្តនយោបាយឈ្នះ-ឈ្នះ (យុទ្ធសាស្ត្រឈ្នះ-ឈ្នះ) ដែលបានរំលាយអង្គការចាត់តាំងខ្មែរក្រហម ធ្វើឲ្យសមាហរណកម្មកងទ័ពខ្មែរក្រហម ឲ្យមករួមរស់ជាមួយរដ្ឋាភិបាលនៅឆ្នាំ១៩៩៨ នាំមកនូវសន្តិភាពរូបនីយកម្មនៅកម្ពុជា។

(មតិផ្សេងៗទៀត)

**៣០.** ចូរពណ៌នាពីសមិទ្ធផលរបស់រដ្ឋាភិបាលពីឆ្នាំ ១៩៩៣ ដល់បច្ចុប្បន្ន។

ពណ៌នាពីសមិទ្ធផលរបស់រាជរដ្ឋាភិបាលពីឆ្នាំ១៩៩៣ ដល់បច្ចុប្បន្ន៖

- វិស័យនយោបាយ
  - នយោបាយក្នុងប្រទេស
    - ការអនុវត្តនយោបាយ ឈ្នះ-ឈ្នះ បានរំលាយអង្គការចាត់តាំងខ្មែរក្រហម និងធ្វើសមាហរណកម្មកងកម្លាំងខ្មែរក្រហមឲ្យចូលមករួមរស់ជាមួយរាជរដ្ឋាភិបាលនៅឆ្នាំ១៩៩៨ ដោយនាំមកនូវសន្តិភាពរូបនីយកម្មនៅកម្ពុជា
    - រៀបចំការបោះឆ្នោតដោយខ្លួនឯង ប្រកបដោយជោគជ័យទៅតាមលទ្ធិប្រជាធិបតេយ្យ
    - កំណែទម្រង់លើគ្រប់វិស័យ ( រដ្ឋបាល តុលាការ កងកម្លាំងប្រដាប់អាវុធ អប់រំ...)
    - កម្ពុជាកាន់យកលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស
    - រាជរដ្ឋាភិបាល បានអនុវត្តនយោបាយ យុទ្ធសាស្ត្រត្រីកោណ និងយុទ្ធសាស្ត្រចតុកោណ
  - នយោបាយក្រៅប្រទេស
    - ឆ្នាំ១៩៩៩ កម្ពុជាបានចូលជាសមាជិកអាស៊ាន (ASEAN)
    - ឆ្នាំ២០០៤ កម្ពុជាចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក
    - ឆ្នាំ២០០២ និងឆ្នាំ២០១២ កម្ពុជាធ្វើជាប្រធានអាស៊ាន
    - កម្ពុជាមានទំនាក់ទំនងល្អជាមួយប្រទេសក្នុងតំបន់ និងពិភពលោក

( មតិផ្សេងៗទៀត)

- វិស័យសេដ្ឋកិច្ច

  សេដ្ឋកិច្ចកម្ពុជាមានកំណើនជារៀងរាល់ឆ្នាំដែលធ្វើឲ្យប្រជាជនធូធារ៖
  - កសិកម្ម៖ មានកំណើនទិន្នផល ព្រោះសំបូរទីផ្សារ
  - ឧស្សាហកម្ម៖ កំណើនរោងចក្រឧស្សាហកម្ម សហគ្រាស បង្កើនការងារដល់ប្រជាជន
  - ពាណិជ្ជកម្ម ៖ សំបូរវិនិយោគិន សំបូរទីផ្សារ
  - ទេសចរណ៍ ៖ កំណើនភ្ញៀវទេសចរ ដែលបង្កើនការងារ និងប្រាក់ចំណូលដល់ប្រជាជន

- ហិរញ្ញវត្ថុ ៖ មានស្ថិរភាពអត្រាប្តូរប្រាក់
- គមនាគមន៍ ៖ សាងសង់ផ្លូវជាតិ ផ្លូវដែក ស្ពាន អាកាសយានដ្ឋាន កំពង់ផែរ ដោយបំពាក់ប្រព័ន្ធទឹក ភ្លើង ពីទីក្រុង ដល់ជនបទ

(មានមតិផ្សេងទៀត)

- វិស័យសង្គម វប្បធម៌
  - អប់រំសិក្សាធិការ ៖ បង្កើតសាលារៀនគ្រប់កម្រិត គ្រប់ទីកន្លែង និងមានកំណើនធនធានមនុស្ស
  - វប្បធម៌ ៖ ធ្វើការគាស់កកាយវប្បធម៌ឲ្យរស់ឡើងវិញ និងដាក់បញ្ចូលសម្បត្តិវប្បធម៌កម្ពុជាជាបេតិកភណ្ឌពិភពលោក
  - សាសនា៖ សុខដុមនីយកម្មក្នុងសាសនា
  - សុខាភិបាល ៖ បង្កើតមន្ទីរពេទ្យ មណ្ឌលសុខភាព ពីទីក្រុងដល់ជនបទ
  - សិទ្ធិ ៖ ផ្តល់សិទ្ធិដល់ស្ត្រី (សមភាពយេនឌ័រ) ប្រជាជនមានការយល់ដឹងពីច្បាប់ និងមានសណ្តាប់ធ្នាប់ល្អ

( មតិផ្សេងៗទៀត)

**៣១.តើសន្តិភាពដែលសម្រេចបានចាប់តាំងពីឆ្នាំ ១៩៩៨ បាននាំមកអ្វីខ្លះសម្រាប់កម្ពុជា?**

សន្តិភាពដែលសម្រេចបានចាប់តាំងពីឆ្នាំ ១៩៩៨ បាននាំមកឲ្យកម្ពុជានូវការអភិវឌ្ឍជាតិលើគ្រប់វិស័យដូចជា៖

- វិស័យនយោបាយ
  - នយោបាយក្នុងប្រទេស
    - កម្ពុជាបានសុខសន្តិភាព និងមានស្ថិរភាពនយោបាយ
    - មានការបោះឆ្នោតជ្រើសរើសមេដឹកនាំតាមបែបប្រជាធិបតេយ្យ
  - នយោបាយក្រៅប្រទេស
    - ឆ្នាំ១៩៩៩ កម្ពុជាចូលជាសមាជិកអាស៊ាន ( ASEAN)
    - ឆ្នាំ២០០៤ កម្ពុជាចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក
    - ឆ្នាំ២០០២ និងឆ្នាំ២០១២ កម្ពុជាធ្វើជាប្រធានអាស៊ាន
    - កម្ពុជាមានទំនាក់ទំនងល្អជាមួយប្រទេសក្នុងតំបន់ និងពិភពលោក

(មានមតិផ្សេងៗទៀត)

❖ វិស័យសេដ្ឋកិច្ច

សេដ្ឋកិច្ចកម្ពុជាមានកំណើនជារៀងរាល់ឆ្នាំដែលធ្វើឲ្យប្រជាជនធូធារះ

- កសិកម្មៈ មានកំណើនទិន្នផល ព្រោះសំបូរទីផ្សារ
- ឧស្សាហកម្មៈ កំណើនរោងចក្រឧស្សាហកម្ម សហគ្រាស បង្កើនការងារដល់ប្រជាជន
- ពាណិជ្ជកម្ម ៖ សំបូរវិនិយោគិន សំបូរទីផ្សារ
- ទេសចរណ៍ ៖ កំណើនភ្ញៀវទេសចរ ដែលបង្កើនការងារ និងប្រាក់ចំណូលដលល់ប្រជាជន
- ហិរញ្ញវត្ថុ ៖ មានស្ថិរភាពអត្រាប្តូរប្រាក់
- គមនាគមន៍ ៖ សាងសង់ផ្លូវជាតិ ផ្លូវដែក ស្ពាន អាកាសយានដ្ឋាន កំពង់ផែរ ដោយបំពាក់ប្រព័ន្ធទឹក ភ្លើង ពីទីក្រុង ដល់ជនបទ

(មានមតិផ្សេងទៀត)

❖ វិស័យសង្គម វប្បធម៌

- អប់រំសិក្សាធិការ ៖ បង្កើតសាលារៀនគ្រប់កម្រិត គ្រប់ទីកន្លែង និងមានកំណើនធនធានមនុស្ស
- វប្បធម៌ ៖ ធ្វើការគាស់កកាយវប្បធម៌ឲ្យរស់ឡើងវិញ និងដាក់បញ្ចូលសម្បត្តិវប្បធម៌កម្ពុជាជាបេតិកភណ្ឌពិភពលោក
- សាសនាៈ សុខដុមនីយកម្មក្នុងសាសនា
- សុខាភិបាល ៖ បង្កើតមន្ទីពេទ្យ មណ្ឌលសុខភាព ពីទីក្រុងដល់ជនបទ
- សិទ្ធិ ៖ ផ្តល់សិទ្ធិដល់ស្ត្រី (សមភាពយេនឌ័រ) ប្រជាជនមានការយល់ដឹងពីច្បាប់ និងមានសណ្តាប់ធ្នាប់ល្អ

( មតិផ្សេងៗទៀត)

**៣២**.ចូរពណ៌នាពីដំណើរការកសាងកម្ពុជាឡើងវិញចាប់តាំងពីឆ្នាំ ១៩៩៨ មកទល់បច្ចុប្បន្ន។

ពណ៌នាពីដំណើរការកសាងកម្ពុជាឡើងវិញចាប់ពីឆ្នាំ១៩៩៨ មកទល់បច្ចុប្បន្នៈ

❖ វិស័យនយោបាយ

- ឆ្នាំ១៩៩៨ មានការធ្វើសមាហរណកម្មកងទ័ពខ្មែរក្រហម និងកងទ័ពរាជរដ្ឋាភិបាលធ្វើឲ្យមានកម្លាំងឯកភាពគ្នា ដើម្បីស្តារប្រទេសនិងកសាងប្រទេសកម្ពុជាឡើងវិញ
- ក្រោយពីកងទ័ពខ្មែរក្រហមដួលរលំ នៅតាមព្រំដែនមានសុវត្ថិភាព និងការអភិវឌ្ឍ
- ការកម្ទេចរចនាសម្ព័ន្ធអង្គការចាត់តាំងខ្មែរក្រហម
- ការបែងចែកដីធ្លីកាន់កាប់ជាកម្មសិទ្ធិដល់បងប្អូនអតីតខ្មែរក្រហម

- បងប្អូនខ្មែរក្រហមបានទទួលតួនាទី និងបុណ្យសក្តិដែលធ្លាប់មានពីមុន

(មានមតិផ្សេងៗទៀត)

❖ វិស័យសេដ្ឋកិច្ច

- ធ្វើទំនាក់ទំនងពាណិជ្ជកម្មអន្តរជាតិជាមួយអាស៊ាន ប្រទេសក្រៅតំបន់ជាពិសេសជាមួយប្រទេសមហាអំណាចធំៗលើពិភពលោក
- កសិកម្មមានការរីកចម្រើន ដោយរដ្ឋាភិបាលយកចិត្តទុកដាក់ក្នុងការបង្កើតប្រព័ន្ធធារាសាស្ត្រ និងបង្កាត់ពូជ...
- អនុវត្តសេដ្ឋកិច្ចទីផ្សារសេរី កម្ពុជាក្លាយជាកន្លែងវិនិយោគទុនដ៏ទាក់ទាញ
- វិស័យឧស្សាហកម្មមានការរីកចម្រើន បង្កើតរោងចក្រសហគ្រាសតូចធំជាច្រើន ពិសេសរោងចក្រវាយនភ័ណ្ឌសម្រាប់បង្កើនការងារដល់ប្រជាពលរដ្ឋជៀសវៀងការធ្វើចំណាកស្រុក និងកាត់បន្ថយភាពក្រីក្រ
- វិស័យទេសចរណ៍ វប្បធម៌ មានប្រាសាទបុរាណជាច្រើន និងទេសចរណ៍ធម្មជាតិសម្រាប់ទាក់ទាញភ្ញៀវជាតិ និងអន្តរជាតិ

(មានមតិផ្សេងៗទៀត)

❖ វិស័យសង្គម

- ឆ្នាំ១៩៩៨ មកដល់បច្ចុប្បន្នមានសុវត្ថិភាព និងសន្តិភាពពេញលេញ
- ធ្វើឲ្យមានសមិទ្ធផលជាច្រើនកើនឡើងដូចជា៖
  - កសាងសាលារៀនពីមតេយ្យសិក្សារហូតដល់សាកលវិទ្យាល័យ
  - កសាងមន្ទីរពេទ្យ ផ្លូវថ្នល់ ស្ពាន ស្ពានអាកាស ប្រព័ន្ធធារាសាស្ត្រ ជាពិសេសសេដ្ឋកិច្ចមានការរីកចម្រើន និយាយរួមគឺមានការរីកចម្រើនលើគ្រប់វិស័យ

❖ វប្បធម៌

- ការបង្កើតពហុកីឡាដ្ឋាន បណ្តុះបណ្តាលជំនាញ ធ្វើឲ្យកីឡាករមានសមត្ថភាពក្នុងការប្រកួតប្រជែងលើឆាកអន្តរជាតិ
- អភិរក្សសម្បត្តិវប្បធម៌ រូបិយ អរូបិយ ព្រមទាំងដាក់បញ្ចូលសម្បត្តិវប្បធម៌ជាបេតិកភណ្ឌពិភពលោក ( រមណីយដ្ឋានអង្គរ ប្រាសាទព្រះវិហារ ប្រាសាទសំបូរព្រៃគុក របាំព្រះរាជទ្រព្យ...)

(មានមតិផ្សេងៗទៀត)

❖ ការអនុវត្តច្បាប់

- មានការទប់ស្កាត់ការជួញដូរមនុស្ស ការជួញដូរគ្រឿងញៀន និងអំពើភេរវកម្ម

- មានសេរីភាពផ្នែកសារព័ត៌មាន និងអនុញ្ញាតឲ្យមានសិទ្ធិសេរីភាព ក្នុងការបង្កើតអង្គការសង្គមស៊ីវិល
- សមភាពយេនឌ័រ ( ផ្តល់សិទ្ធិដល់ស្ត្រី)។

(មានមតិផ្សេងៗទៀត)

៣៣.ចូរអ្នកពណ៌នាពីការអភិវឌ្ឍសេដ្ឋកិច្ច សង្គមនៅកម្ពុជាពីឆ្នាំ១៩៩៣ មកទល់សព្វថ្ងៃ?

ការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកម្ពុជាឆ្នាំ១៩៩៣ មកទល់សព្វថ្ងៃមានដូចជា៖

- នយោបាយឈ្នះ-ឈ្នះ

នយោបាយឈ្នះ-ឈ្នះ បានធ្វើឲ្យរាជរដ្ឋាភិបាលដាក់ចេញនូវ យុទ្ធសាស្ត្រត្រីកោណ និងយុទ្ធសាស្ត្រចតុកោណ ក្នុងការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម តាមរយៈកំណែទម្រង់សាធារណៈ វិមជ្ឈការ កំណែទម្រង់ច្បាប់ ប្រព័ន្ធតុលាការ សមភាពយេនឌ័រ ហិរញ្ញវត្ថុសាធារណៈ លុបបំបាត់អំពើពុករលួយ ការគ្រប់គ្រងធនធានធម្មជាតិ ប្រកបដោយចីរភាព

- វិស័យសេដ្ឋកិច្ច
  - បង្កើនទំនាក់ទំនងពាណិជ្ជកម្មអន្តរជាតិជាមួយអាស៊ាន និងមហាអំណាចធំៗលើពិភព-លោក
  - កសិកម្មមានការរីកចម្រើនដោយរដ្ឋាភិបាលយកចិត្តទុកដាក់ក្នុងការបង្កើតប្រព័ន្ធធារាសា-ស្ត្រ ការបង្កាត់ពូជ ការប្រើប្រាស់ដី
  - អនុវត្តសេដ្ឋកិច្ចទីផ្សារសេរី កម្ពុជាក្លាយជាកន្លែងវិនិយោគទុនដ៏ទាក់ទាញ
  - ជំរុញ និងលើកទឹកចិត្តការវិនិយោគពីឯកជន បង្កើនទុនពីបរទេស
  - ជំរុញវិស័យឧស្សាហកម្មមានការរីកចម្រើន ផ្នែករោងចក្រសហគ្រាសតូចធំជាច្រើន ពិសេសរោងចក្រវាយនភ័ណ្ឌសម្រាប់បង្កើនការងារដល់ប្រជាពលរដ្ឋជៀសវៀង ការធ្វើចំណាកស្រុក និងកាត់បន្ថយភាពក្រីក្រ
  - ជំរុញឲ្យមានការយកចិត្តទុកដាក់លើវិស័យទេសចរណ៍ វប្បធម៌ និងទេសចរណ៍ធម្មជាតិសម្រាប់ទាក់ទាញភ្ញៀវជាតិ និងអន្តរជាតិ
  - ធ្វើឲ្យអត្រាប្តូរប្រាក់មានស្ថិរភាព
  - ចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក (២០០៤)
- វិស័យសង្គម
  - ឆ្នាំ១៩៩៣ ដល់បច្ចុប្បន្នរាជរដ្ឋាភិបាលបានរៀបចំសណ្តាប់ធ្នាប់សង្គម រក្សាសន្តិសុខសុវត្ថិភាព និងសន្តិភាពពេញលេញ

- ធ្វើឲ្យមានសមិទ្ធផលជាច្រើនបានកើនឡើងដូចជា៖
  - កសាងសាលារៀនពីមតេយ្យសិក្សារហូតដល់សាកលវិទ្យាល័យ
  - កសាងមន្ទីរពេទ្យ ផ្លូវថ្នល់ ស្ពាន ស្ពានអាកាស ប្រព័ន្ធធារាសាស្ត្រ ជាពិសេសសេដ្ឋកិច្ចមានការរីកចម្រើន
  - ប្រជាជនមានជីវភាពកាន់តែប្រសើរ

❖ ការអនុវត្តច្បាប់

- មានការទប់ស្កាត់ការជួញដូរមនុស្ស ការជួញដូគ្រឿងញៀន និងអំពើភេរវកម្ម
- មានសេរីភាពផ្នែកសារព័ត៌មាន និងអនុញ្ញាតឲ្យមានសិទ្ធិសេរីភាពក្នុងការបង្កើតអង្គការសង្គមស៊ីវិល
- សមភាពយេនឌ័រ ( ផ្តល់សិទ្ធិដល់ស្ត្រី)។

( ចម្លើយត្រឹមត្រូវផ្សេងៗទៀត )

ដកស្រង់ចេញពីការបង្រៀនពីចម្ងាយ ( E- Learning) របស់ ក្រសួងអប់រំ យុវជន និងកីឡា